កាលនោះល្បីឈ្មោះបណ្ឌិតទុំ នៅខេត្តត្បូងឃ្មុំប្រុសប្រាជ្ញប្រាយ
ចេះច្រៀងឆ្លាស់រឿងសុសសព្វសាយ ក្នុងដែនដីអាយប្រៀបពុំបាន ។
មួយទៀតមានឈ្មោះបណ្ឌិតពេជ ជាស្រេចចេះភ្លេងល្បែងប៉ុន្មាន
ព្វល្បីឈ្មោះអ្នកទាំងពីរប្រាណ ក្សត្រក្សាន្តទ្រង់មានរាជឱង្ការ ។
៤៥៥. ស្តេចត្រាស់បង្គាប់អោយទៅយក ទុំនិងពេជ្រមកថ្វាយក្សត្រា
ចាត់រាជបំរើតាមរាជការ ដោយព្រះចិន្តាទ្រង់ប្រញាប់ ។
បម្រើមឱនអង្គផង់កាមា ទទួលឱង្ការលាក្រឡាប់
ខំស្រូតរូតដល់កំពង់ឆាប់ ដល់អរជូនស្តាប់ព្រះឱង្ការ ។
អរជូនទទួលទុកសិរី ចាត់បម្រើខ្ចីចរយាត្រា
ទៅយកពេជ្រទុំអោយរួសរ៉ា ដូចបន្ទូលថាទ្រង់បង្គាប់ ។
យកទុំនិងពេជ្របានមកដល់ ឡើងគាល់អរជូនឱនគំនាប់
អរជូនប្រាប់ថាក្សត្រាសព្វ បង្គាប់បញ្ជូនខ្លួនទៅថ្វាយ ។
ពេជ្រទុំបង្គំឥតប្រកែក ថាទៅថ្ងៃស្អែករិះខ្វល់ខ្វាយ
រករៀបប្រដាប់សម្រាប់កាយ ចៅហ្វាយមេត្តាគ្រាប្រណី ។
៤៦០. បម្រើពីហ្លួងថាអាណិត យើងនេះតាមចិត្តឥតថាអ្វី
ប៉ុន្តែអ្នករួសអោយឆាប់ខ្ចី ត្បិតព្រះចក្រីត្រាស់បង្គាប់ ។
គ្រានោះបណ្ឌិតទុំនិងពេជ ដឹងច្បាស់រឿងស្រាចវិលលីលាប់
លាកលាអរជូនវិលត្រឡប់ ថ្លែងសព្វដំណើរប្រាប់ទាវស្រី ។
ទាវអើយត្បិតមានព្រះតម្រាស់ ប្រាកដជាក់ច្បាស់ពីចក្រី
អោយយកខ្លួនបងទៅឆាប់ខ្ចី បងសូមលាស្រីថ្លៃឧត្តម ។
ទាវឆ្លើយថាឱអ្នកថ្លៃអើយ ទុក្ខប្អូនឥតស្បើយរីងក្រៀមក្រំ
ប្អូនទប់មិនបានក្សាន្តទ្រទ្រាំ ទុក្ខមាំក្នុងខ្លួនប្អូនមិនស្បើយ ។
ទុំថាឱថ្លៃនីមនួនល្អង សព្វថ្ងៃបានបងនៅក្បែរកើយ
ពីនេះទៅស្អែកបែកគ្នាហើយ ទាវអើយប្អូននៅកុំទុក្ខា ។



៤៦៥. ទាវថាឱទុក្ខប្អូនខ្លាំងម្ល៉េះ មិនមានរបេះទៅត្រង់ណា
ប្អូនប្រាសប្រុសថ្លៃថ្លើមសង្សារ ទាវខំប្រវ៉ារៀបផ្គូផ្គង ។
សំពត់ស្លាម្លូមូរបារី រៀបដាក់ហិបថ្មីអោយទុំផង
រួចទាវផ្តែផ្តាំថាអ្នកបង ទៅហើយវិលផ្គង់ឆាប់រួសរ៉ា ។
វិលមកយកប្អូនណាំអ្នកថ្លៃ ប្អូននៅក្រំក្សៀយបង់អសារ
ទុំថ្នមបីបមថើបភ័ក្ត្រា ប្រវ៉ាឱបទាវកែវកល្យាណ ។
លង់លុះព្រឹកព្រាងស្វាងឡើងជាក់ តែងតួស្លៀកពាក់ចរចេញឋាន
បម្រើពីហ្លួងក៏ស្មោះស្មាន បណ្ឌិតពីរប្រាណត្រាច់យាត្រា ។
ទុំគិតពិនិត្យជម្រាបទៅ ខ្ញុំនេះឥឡូវសុំមេត្តា[១]
ជូនទៅបាភ្នំសួរមាតា នូវគ្រូអាចារ្យមីងមាផង ។
៤៧០. បម្រើស្តាប់ហើយមិនមានខាន ថាជូនទៅបានដូចបំណង
អោយបានលាម្តាយនូវរៀមច្បង ចរចេញត្រសងមិនសង្ស័យ ។
រួចដើរកាត់ព្រៃខេត្តត្បូងឃ្មុំ ស្តាប់សត្វយាសយំទុំអាស្រ័យ
ឈ្មោលញីទាំងពីរយំច្រៀងច្រៃ ស្រមៃដូចទាវនៅនៃបនិត្យ ។
ទុំថាឱទាវនីមនួនល្អង ថ្ងៃនេះអញបងឃ្លាឃ្លាតពិត
មិនបានរួមស្ថានដួងជីវិត ម្ល៉េះសមឆោមស្និទ្ធនៅកំព្រា ។
ដើរហើយពុំស្បើយរីងចង្អៀត ខំឆ្លៀតរំពៃក្នុងអធ្វា
ទុំរាប់ដើមឈើផងនានា ដុះខាងមាគ៌ាជាជួរជ្រៃ ។
មើលមានជ្រៃជ្រៃសង្កែថ្ងាន់ គ្រៀលត្រសក់ក្រវាន់គុយស្រគំ
ស្រឡីស្រឡៅក្រពៅក្តុម្ព ទ្រទំអាអូដ្ឋអង្គុរត្នាត ។
៤៧៥. ដង្កោទ្រយឹងខ្ទិងក្រសាំង អំពិលភ្លូងភ្លាំងទាំងភ្លូបាត
គូលែនទុរេនមានលាំងសាត មាក់បាតបង្ក្តៅព្នៅចាន់ចារ ។
ត្របែកត្រសេកអំបែងថ្ងៃ អង្ក្រងស្មាច់ស្មែរោគរកា

១. ច្បាប់ខ្លះថា ទុំប្រាប់បំរើដឹងជាច់ ថាខ្ញុំនេះសូមលោកមេត្តា ...

ក្រួចក្រាយស្វាតស្វាយត្រាចត្រៀលស្វា សេដាសណ្ដាន់ថ្នាន់ជ្រៃជ្រៃ ។
មានទាំងដកពាយវាយដកព សង្ស៊ីរពង្ររាក់រាំងស៊ី
ភ្កាំភ្លែងផ្ដៃស្រែងលោតលាំងដៃ សន្ទែក្រខុបងុបក្រឡាញ់ ។
ច្រមាស[១] បុស្សនាគច្រកែងទូយ ប្រផេញគោមូយឈើទាលត្រាញ់
រាជផ្លិសផ្ចេញត្រីរែអញ្ចាញ អង្កាញ់អង្កោលកណ្ដោលបាត ។
ត្រាចត្រៀកចង្រៀកច្រេសខ្ទឹមក្ដុម្ព គគីររាំងភ្នំបេងបាយម៉ាត
ស្គុកស្គុរស្ដិស្ដៅត្រាវក្ដួចក្ដាត លាំងសាតសត្បារការស្រល់ ។
៤៨០. ទុំដើរក្នុងព្រៃរំពៃសត្វ ស្រង្វូតស្រងាត់ក្នុងចិត្តសល់
វិតក្កក្នុងកាយគិតខ្វាយខ្វល់ នឹកដល់ទាវស្រីមិនមានស្បើយ ។
ទុំមៀងមើលយល់ផលបុប្ផា ហើយសសើរថាឱផ្កាអើយ
ផ្កាដុះនៅនិត្យជិតបង្អើយ ពិដោរមកហើយក្លិនថ្មីៗ ។
ពិដោរផលាផ្កាកំភ្លឹង ដូចបងនៃបនឹងទាវពិសី
ពិដោរបុប្ផាផ្កាចំប៉ី ដូចបងនៃបស្រីទាវឥតហ្មង ។
ចម្ប៉ាចំពើបទើបជួបគ្នា ឥឡូវឃ្លាតឃ្លាទាវនួនល្អង
រំដួលអន់អួលពេកកន្លង ចិត្តបងអាល័យផ្លែកន្ទិដ្ឋា ។
ឱបងពិដោរផ្កាក្រវាន់ ដូចក្លិនទាវស្បាន់ជិតកាយា
ពិដោរថ្មីៗដូចក្លិនផ្កា ជាប់នៅជាយផាហ៊ុមក្រវាត់ ។
៤៨៥. ដើរដោយវាលវែងត្រែងដុះត្រា ទន់ទាបសុរិយាយាត្រាកាត់
មៀងមើលមេឃមិរពពកសាត់ ដូចកលបងខ្វាត់ពីទាវមក ។
កន្លង់ក្រឡឹងផ្កាក្រឡាញ់ ដូចខ្លួនអង្គអញត្រាច់ដើររក
ពពេចពពូលហើរចូលជ្រក ដូចអង្គអញមកនៅរូមកាយ ។
គ្រលីងគ្រលោងគ្រលែងវែក ក្រឡុះហើរបែកគូហ្វូងហ្វាយ
ដូចបងបែកទាវថ្លៃឆោមឆាយ មកដល់ស្ថានអាយអង្គឯកា ។

១. ច្បាប់ខ្លះថា កប្បាស



ឱបងស្រណោះសត្វតាវៅ យំក្នុងព្រៃជ្រៅសព្វភាសា
ហាក់មាត់ទាវស្ងួននួនកន្និថា ចរចាសាសងបងស្រមៃ ។
ត្រយងយំឆ្លងឆ្លើយគូវា ហើរហើយបែកគ្នានៅច្រៀវច្រៃ
ដូចខ្លួនអង្គអញបែកទាវថ្លៃ យូរថ្ងៃពុំសុខទុក្ខឥតស្បើយ ។
៤៩០. បងស្ដាប់សូរស័ព្ទរៃកណ្ដឹង មាន់ព្រៃប្រប្រឹងរងាវឆ្លើយ
បងនឹករលឹកទាវទៀតហើយ ទាវអើយសមស្ងួននួនកំព្រា ។
ដើរដោយព្រៃជ្រោងរំលងជ្រៅ ទទាហៅទៅទំទឹមគ្នា
ត្រសិតត្រសងហើរវេរា សេកនាំគូវាសសៀវទំ ។
សារិកាស្រែករកគូសប្បាយ ហើរឆ្ងាយនាំញីស៊ីស្រគំ
សព្វសត្វច្រវាត់ក្នុងព្រៃភ្នំ យាសយំឆ្លើយឆ្លងសងសម័យ ។
ថ្លាថ្លែងសម្ដែងទុំនិងពេជ្រ ខំស្រូតដើរត្រាច់ទាំងយប់ថ្ងៃ
បានដល់ភូមិស្រុកទុក្ខអាល័យ ជួបម្ដាយប្រស្រ័យសួរទៅមក ។
ទុំបានសាស័ព្ទប្រាប់ម្ដាយថា ខ្ញុំកូនមានការស្ដេចអោយយក
ខ្លួនខ្ញុំនិងពេជ្របួនពន្លក ទ្រង់ភ្នកហប្ញទ័យល្បីទៅដល់ ។
៤៩៥. ជាអ្នកចម្រៀង[១] ល្បែងល្បីល្បាយ ហេតុនេះលោកម្ដាយសុំតម្កល់
កុំអាក់កំអន់កុំអោយសល់ ស្ដេចស្គាល់ក្រមានក្នុងឋានអាយ ។
នាងម្ដាយទុំស្ដាប់ស័ព្ទសម្ដី កូនប្រាប់គប្បីអ្នកមាសម្ដាយ
បើកូនអ្នកទៅប្រយ័ត្នកាយ ចូរថ្វាយខ្លួនអ្នកអោយជាក់ស្ដែង ។
កុំបាធ្វេធ្វេសប្រហែសខ្លួន កុំឃើញស្រីយួនពួនប្រឡែង
ប្រយ័ត្នកំចាត់នៅខាងល្បែង ខំស្វែងខំស្វះលះពីអាយ ។
ទុំក្រាបប្រណិប័តន៍ហត្ថសំពះ លាម្ដាយរហ័សទាំងពីរកាយ
ដើរទៅដល់វត្តប្រាកដថ្វាយ បង្គំរាប់រាយដំណើរប្រាណ ។
ឱនអង្គក្រួញក្រាបទាំងពីរអ្នក លោកគ្រូស្មោះស្ម័គ្រព្រះទ័យក្សាន្ត

១. ច្បាប់ខ្លះថា កូនចេះច្រៀង ....។

មានពុទ្ធដីកាសួរចង់ដឹងដាន    ទុំសោកទូលថ្លានមិនមានល្បែង ។
៥០០. ទូលថាស្តេចចាត់បម្រើមក    ដល់ហើយរើសយកជាចម្រៀង
ទៅគាល់បំរើជាភីល្បែង    គ្រូផ្សៀងស្តាប់ជាក់ភ្ញាក់ស្មារតី ។
ពុទ្ធដីកាថាអើបម្រើក្សត្រ    យប់ថ្ងៃប្រយ័ត្នខ្លួនកុំបី
កុំបាចូលចិត្តស្និទ្ធនឹងស្រី    ខ្លាចអង្គចក្រីយកទោសា ។
បានចូលគាល់ក្សត្រប្រយ័ត្នប្រាណ    ដំណេកទីឋានអង្គក្សត្រា
កុំចូលពេលស្ងាត់ប្រយ័ត្នការណ៍[1]    គាល់អង្គក្សត្រាព្រះបពិត្រ ។
កុំបាប្រកួតនឹងចេស្តា    ខ្លាចបរមីតាព្រះទ្រង់រិទ្ធិ
ព្រះអគ្គមហេសីកុំទៅជិត    នឹងបង់ជីវិតពីព្រោះស្រី ។
ពេជ្រទុំប្រណម្យស្តាប់ពុទ្ធដីកា    ក្រួញក្រាបបហត្ថាដាក់សិរសី
បង្គំលាគ្រូចរចុះដី    ចេញចាកឃ្លាតខ្ញីចាំពុទ្ធដីកា ។
៥០៥. បំរើពីហ្លួងទាំងពួងនាំ    ទុំពេជ្ររៀបចំចរយាត្រា
ដើរដល់កំពង់រង់ត្បិតថា    ដោយនូវអាជ្ញារួសឆាប់វៃ ។
ចុះទូកចែវតាមទឹកទន្លេ    ទុំគិតគ្នាន់គ្នេររិះរំពៃ
លង់លុះសុរិយាទៀបបាំងព្រៃ    ទុំនឹងសន្ទៃអន់អួលផ្សា ។
ដំណើរទុំទុកស្នេះបង្អង់    ថ្លែងទៅទាវផ្ចង់ប្រុងអត្ថា
តាំងពីទុំឃ្លាតឃ្លាកាលណា    ទាវកើតទុក្ខាពុំមានក្សាន្ត ។
ចំណីបាយទឹកមិននឹកនា    សាច់ជ្រូកមានទាពោរពេញចាន
សល់នៅក្រៀមផ្អោះស៊ីមិនបាន    រំខានវិយោគសោយសោកា ។
ទាវថាឱះឱប្រុសខ្លីមចិត្ត    បូនធ្លាប់ស្នាលស្និទ្ធិរួមស្នេហា
ឥឡូវឃ្លាតឃ្លារៀមភស្តា    ចិន្តាបូនទ្រាំក្រំមិនស្បើយ ។
៥១០. នាងនោលួងលោមឃាត់ទាវថា    កុំអោយសោកាណាំថ្ងៃអើយ
យូរឆាប់គង់ជួបពុំលែងឡើយ    ទាវអើយបងឃាត់អត់កំសាន្ត ។

១. ច្បាប់ខ្លះថា ណាំអ្នកណាំ



ទាវស្តាប់នោះប្រាប់សព្វសេចក្តី    រសាយទុក្ខខ្ញីគ្រាន់ស្រាកស្រាន្ត
នោះនាំទាវស្រីចរចូលថ្លាន    សម្រាន្តលង់លក់លើសយនា ។
ដំណើរទាវទុំបង្អង់នៅ    និយាយតទៅទុំទុក្ខា
ចែវទូកស្រូតរូតតាមគង្គា    មៀងមើលមច្ឆាហែលរហង់ ។
រ៉ស់ឆ្តោកកោរាជរាហូ    ព្រួលប្រាទីពោព្រុយកន្លង់
ដំរីក្អិតក្អីប្ញូស្សិច-    ង្វាភ្លៀងរហង់រហ័សហែល ។
សណ្តាយក្រុសក្រាយឆ្អិនច្រកែង    ផ្ទក់ក្រាញ់អណ្តែងច្រើនក្រាស់ក្រែល
សរសៃកំពតផ្សោតប្រប៉ែល    ផុសផែលផុលផុងក្នុងគង្គា ។
៥១៥. ឆ្លូញស្លាតសង្វាតសៀវសៀតក្បែរ    ច្រកែងកែសកែត្រំគជ្រោ
ប្លាម៉ាប៉ាមូចូលរោ    រូងរាមនាំគ្នាហែលត្រសង ។
ព្រលីតដុះជិតដើមត្រកៀត    ត្រកួនដុះបៀតដូចអង្គបង
ត្រកៀតដុះបៀតដូចនួនល្អង    ត្រកួនដូចបងត្រកងបី ។
ព្រលូងពាំផ្កាព្រលីតលង    ទំនងដូចបងប្រឡែងស្រី
ឥឡូវនិរាសប្រាសចេញខ្ញី    ម្លេះហើយសមបីទន្ទឹងផ្លូវ ។
យើងនឹងថ្លែងស្រូតរូតសាសព្វ    មិនមានរៀបរាប់ផ្ទាប់តម្រូវ
ផ្លែងកាលចែវទូកលឿនដល់ទៅ    ចាប់ចតឈប់នៅកំពង់ហ្លួង ។
ឡើងដើរមឿងមើលអស់ទំនិញ    អង្គុយលក់ទិញហូលផាមួង
គ្រប់សាសន៍គ្រប់សែខ្មែរទាំងពួង    រួចមុខក្រសួងនាំរួសរៃ ។
៥២០. ទៅដល់ជើងវាំងអង្គក្សត្រា    បម្រើនាំសារថ្វាយចក្រី
នាំទុំនិងពេជ្រស្រេចឥតបី    ដល់ក្សត្រនរបតីអង្គឥស្សរា[1] ។
កាលអើយកាលនោះព្រះចមពង្ស    ក្សត្រាស្តេចទ្រង់ព្រះបញ្ជា
បង្គាប់អោយក្រុមមុខបណ្តា    ត្រូវការរៀបចំអោយទុំច្រៀង ។
ក្រុមការរៀបរួចស្រេចសព្វគ្រប់    ចូលទូលចមភពមិនមានល្បៀង

១. ច្បាប់ខ្លះថា រាមា។

ស្តេចរៀបស្រីស្នំក្រុមភិលៀង អង្គុយគាស់រៀងតាមលំដាប់ ។
បណ្ឌិតពេជ្រទុំផ្តុំហត្ថា ដាក់លើសិរសាប្រវាំចាប់
ចាប៉ីសាដៀងដេញប្រញាប់ ទុំស្រែកសាស័ព្ទសងឆ្លងឆ្លើយ ។
ព្រះគុណប្រកបមានតេជៈ តបៈបារមីឥតស្មើឡើយ
ទ្រង់មានចិន្តាត្រាស់ទៅហើយ ម្ចាស់អើយទ្រង់ភ្ញាកយកខ្លួនខ្ញុំ ។
៥២៥. ជាអ្នកចម្រៀងច្រៀងប្រការ ប្រកបចេស្តាប្រោសសូមសុំ
ទោះទោសឆ្នាំឆ្លងហ្មងពិតពុំ ត្រឹមត្រូវត្បិតក្រុមជំនុំក្រៅ ។
ស្រែស្រុកខែត្រខណ្ឌខាងត្បូងឃុំ ចូលមកបង្គំច្រើនល្ងង់ខ្លៅ
ទ្រង់ប្រោសប្រណីសេចក្តីឆៅ ខ្លួនក្មេងក្រែងហៅដៅដល់អង្គ ។
មិនមានរំអែងក្រែងចេស្តា សូមទ្រង់មេត្តាប្រោសស្រោចស្រង់
គង់កើតជាខ្ញុំក្រុមក្រោមល្អង- ធូលីទ្រង់សង្គ្រោះប្រោសប្រាណ ។
ស្តេចទ្រង់សំរួលស្រួលព្រះទ័យ ទុំអើយគប្បីអញគិតស្មាន
ថាឯងមិនផេះក្នុងជើងក្រាន បើម្លេះសមខានមិនបានទៅ ។
ស្រុកភូមិទេតើទុំកុំភ័យ កុំគិតនឹកអ្វីចូរឯងនៅ
អញអោយរបស់យសស័ក្តិត្រូវ ទុំឯងអោយហៅថាម៉ឺនឯក ។
៥៣០. ម៉ឺនឯកចែកឈ្មោះយសស័ក្តិថ្មី ស្តេចទ្រង់ប្រណីខ្លាំងអនេក
នៅឃើតយូរថ្ងៃវិស័យបែក ទុំភ្ញាកសង្វេគសង្វែងបង់ ។
នឹកទាវទៀតទុក្ខមុខក្រៀមក្រំ ទោមនស្សបារម្ភប្រាថ្នាត្រង់
អោយជួបទាវស្រីជាសាច់ស- ង្សារសូមព្រះអង្គទ្រង់ប្រោសប្រាណ ។
កាលអើយកាលនោះទ្រង់ព្រះយស បុណ្យខ្ពស់ចក្រពង្សទ្រង់កំសាន្ត
ភ្ញាកក្នុងព្រះទ័យវៃស្មោះស្មាន ឱង្ការឈ្វេងយល់ដល់សង្សារ ។
នៅនគរកម្ពុជានាដែនភព ខេត្តខណ្ឌគ្រាន់គ្រប់រាជសីមា
អញចង់ចាត់រកយកស្រីណា មានលក្ខណាសមជាមហេសី ។
ស្រីចិនយួនចាមតាមសក្តា កុំថាតាមអញសព្វព្រះទ័យ
ទោះខ្មែរស្រុកស្រែចំការក្តី រូសរៃកុំបីគិតកោតក្រែង ។



៥៣៥. ទ្រង់មានចិន្តាកាលណាឈប់[១] ស្តេចត្រាស់បង្គាប់ជៀងជាក់ស្តែង
អោយហៅកុង្សៀយ៍បតីតែង បន្ទូលចាត់ចែងរើសមហេសី ។
សេនាចាត់ការតាមដោយហេតុ ចេញទៅគ្រប់ខែត្រឯកទោត្រី
បម្រើនាំសារក្នុងបូរី ចាមចិនខ្មែរក្តីមន្ត្រីរាស្ត្រ ។
ខ្លះចេញទៅទ្រាំងខេត្តខាងក្រោម ភូមិកំពង់សោមបន្ទាយមាស
បាទីព្រៃកប្បាសច្រឡាសស្វាស ទៀយហាត់ឈប់ឈ្លៀសសេះដីរ ។
ជិះបរទៅខេត្តសំរោងទង ភ្នំស្រួចខេត្តថ្ពងគងពិសី
សង្ខាតអោយហាតខំឃ្មាតខ្មី រកស្រីផងគ្មានធ្យានរំពឹង ។
ឡប់ពីបាទីព្រៃកប្បាស អរបានស្រឡះដើរវិលវឹង
ចូលរកខេត្តស្អាងកណ្តាលស្ទឹង ពុំដឹងព្រួយចិត្តគិតស្រូតឆ្លង ។
៥៤០. ទៅខេត្តលង្វែករលាប្អៀរ សសៀរទៅដល់ខេត្តខ្លុងក្រង
ខ្លះទៅពោធិ៍សាត់បាត់ដំបង ឆ្លងស្ទឹងបាត្រៃកំពង់ស្វាយ ។
ដើរកាត់ចាត់ចូលខេត្តជើងព្រៃ កំពង់សៀមវៃដល់បារាយណ៍
ខ្លះចេះវេះគេចទៅរៀងអាយ កៀនស្វាយល្វាឯមពាមតាឯក ។
ទៅខេត្តរំដួលចូលស្វាយទាប រៀងរាបបត់ទៅរមាសហែក
ទៅរកពាមជរមកលើកដែក ដើរបែកដល់ស្រុកមុខកំពូល ។
ខ្លះដើររកក្បៀរមាត់ទន្លេ មិនបានគិតគ្នេរនាំគ្នាចូល
បង្គំទ្រង់រិទ្ធិនឹងពិតទូល ឆ្ងាយជិតមកមូលទូលចមត្រៃ ។
ទូលចប់ត្រឡប់លាភូបាល ឡើងខ្សាច់កណ្តាលត្បិតសង្ស័យ
បាភ្នំព្រៃវែងទទឹងថ្ងៃ ក្រក្រែមិនបានដូចបំណង ។
សៀវសឹករកក្នុងខេត្តរមាស ភ័យស្វាសគិតឈ្លៀសរកទូកឆ្លង
ចៃវស្រូតរហូតដល់ស្ទឹងត្រង់ សៅហ្មងព្រួយចិត្តគិតឈប់ឈរ ។
ប៉ុន្តែព្រួយប្រឹងនឹងរាជការ ឡើងសារទៅខេត្តឆ្លូងកញ្ជរ

១. ច្បាប់ខ្លះថា ...ប្រាថ្នាជា ។

ក្រចេះក្រួចឆ្មាររកាខ្នុរ ស្រុកលោលបមកសួងសង្កែ ។
លង់លុះដល់ដែនខេត្តត្បូងឃ្មុំ អរជូនជាធំមានចិនខ្មែរ
ចាមជ្វាចំនៀរខាងស្រុកស្រែ ដើរហែមៀងមើលមិនត្រូវចិត្ត ។
ដល់ពោធិជើងខាលមានអណ្ដូង ឃើញមនុស្សជ្រួលច្រងឈរប្រកិត
អាជ្វាខាងហ្លួងទាំងពួងពិត មើលគ្មានពេញចិត្តដល់មួយឡើយ ។
លងលុះសុរិយទេរត្រជាក់ ទាវស្រីវរលក្ខណ៍ចេញលំហើយ
អាជ្វារិកមុខទុក្ខផងស្បើយ ថាគ្នាយើងអើយពេញហៅល្អ ។
៥៥០. យើងដើររកសព្វក្នុងបុរី មិនបានរូបស្រីស្រស់បវរ
អាជ្វាទាំងនោះឆ្កោះស្មោះសរ អំណរពេកពិតឥតស្មើបាន ។
ចាំគ្នាមើលមៀងផ្ទៀងអង្គកាយ អង្គីដែនអាយកបកល្យាណ
សមជាមហេសីមហាក្សត្រក្សាន្ត ស័ក្តិសមអង្គប្រាណស្រស់ប្រិមប្រិយ ។
អាជ្វាខាងហ្លួងទាំងពួងសួរ រាស្ត្រផងគាប់គួរលុតលើកដៃ
ថាទាវល្អមែនហើយម្ចាស់ថ្លៃ សព្វថ្ងៃបានទៅកូនអរជូន ។
អាជ្វាឈ្លបឆ្មៀតសង្កេតសួរ ចូរប្រាប់គាប់គួរអោយមែនមួន
ការហើយឬគ្រាន់តែជំនូន កុំឡិបបំពូនលាក់លេងឡើយ ។
រាស្ត្រភ័យលើកដៃជម្រាបថា ថ្នាក់ត្រឹមស៊ីស្លាទេលោកអើយ
ជម្រាបតាមត្រង់ប៉ុណ្ណឹងហើយ ស្ដាប់ពាក្យរាស្ត្រឆ្លើយមិនសង្ស័យ ។
៥៥៥. ទើបនាំឱង្ការទៅប្រញាប់ ខំស្រូតអោយឆាប់ទាំងយប់ថ្ងៃ
ដល់ឡើងអរជូនឱនលើកដៃ ខ្លាចបារមីថ្លៃរសម្ពីម្ពា ។
ទៅដល់ម្ដាយទាវហើយប្រាប់ថា បន្ទូលព្រះមហាក្សត្ររាជា
អោយនាំទាវទៅកុំរួញរា ថ្វាយព្រះរាជាស្ដេចទ្រង់រិទ្ធិ ។
ម្ដាយទាវបានស្ដាប់បន្ទូលថ្លៃ ឱនក្រាបលើកដៃបង្គំគិត
ប្រាប់ញាតិសន្ដានបានដឹងពិត នាំទាវឆោមស្និទ្ធិទៅថ្វាយស្ដេច ។
អរជូនរួសរាន់រៀបទូកក្តារ ប្រគប់អាជ្វាប្រដាប់ស្រេច
ទូកមួយទាវជិះល្អបណ្ដាច់ ញាតិសាច់បងប្អូនជូនទាវទៅ ។



កាលនោះម្ដាយទាវគិតជំនុំ នឹងអស់ចាស់ទុំថាឥឡូវ
យើងស្មាងទាវកូនអោយត្រឹមត្រូវ រួចចរចុះទៅទូកម្ពីម្ពា ។
៥៦០. កំណែនច្រូងច្រាងខាងជើងទឹក ចាប់ចែវរញ៉ឹកគ្រប់រាល់គ្នា
ខ្លះវាតខ្លះឆាកល្បៀកគាស់វា ទាវលាសណ្ដានច្រានចេញទៅ ។
ជិះទូកពុំសុខទុក្ខពុំស្បើយ ទាវថានោអើយយើងឥឡូវ
បងជួយគិតប្អូនអោយត្រឹមត្រូវ គេយកប្អូនទៅថ្វាយស្ដេចហើយ ។
បងមិនអាណិតចិត្តប្អូនផង ទុក្ខធ្ងន់កន្លងពុំមានស្បើយ
សមប្អូនក្សិនក្ស័យទេដឹងអើយ ទុក្ខអើយទោម្នេញពេញជាថ្មី ។
ទុក្ខមួយព្រួយព្រោះអង្គក្សត្រា យកជាសង្សាររួមបេតី
ទុក្ខមួយឃ្លាតទុំឆោមពិសី រស់ថ្មីសូវស្លាប់ទៅក៏ជា ។
កើតមកជាមនុស្សក្នុងលោកិយ៍ ចាប់ជាតិជាស្រីរងវេទនា
សង្សារសម្លាញ់ក៏ឃ្លាតឃ្លា វេទនាចិត្តអ្វីអីម្ល៉េះណា ។
៥៦៥. ម្ដាយទាវជិះទូកទៅជាមួយ ប្រុសស្រីរង្គួយមិនដឹងការ
គិតស្មានទាវស្ម័គ្រនឹងក្សត្រា អរឥតឧបមានាំទាវទៅ ។
ទាវសោតជាទុក្ខមុខក្រៀមក្រំ ខំអត់ទ្រទ្រាំនាំកំឡានៅ
កណ្ដែងកណ្ដោចកណ្ដាលផ្លូវ ទូកសោតល្បឿនទៅដោយរលក ។
សាត់លយលន់ល្បឿនពន់ប្រមាណ ព្រះពាយផាត់ច្រានវិលពពក
អណ្ដែតលយសាត់ខ្ចាត់ទៅមក ចូលជ្រកបាំងវង់ព្រះចន្ទ្រា ។
ទាវថាឱអង្គព្រះច័ន្ទថ្លៃ ពណ៌ដូចចរណៃលើវេហាស៍
ដូចខ្លួនខ្ញុំបែងបង់ឃ្លាតឃ្លា រស្មីចន្ទ្រាក៏ត្រជាក់ ។
តារារះរុងរឿងជិតជុំ ដូចអញនឹងទុំធ្លាប់រួមរ័ក្ស
តារារះរាយដោយចង្វាក់ ដូចអង្គអញស្ម័គ្រទុំថ្លើមថ្លៃ ។
៥៧០. លង់លុះម៉ោងប្អូនជូនយប់ស្ងាត់ ព្រះពាយផាយផាត់ត្រជាក់ក្រៃ
ទាវភ្ញាក់នឹកទុំព្រោះអាល័យ មមៀលលើកដៃឈោងប្រវា ។
លុះភ្លឺស្រាងស្រេចបំព្រាងខ្ចី ទាវស្រីតយគន់ហ្វូងមច្ឆា

ហក់ហែលផស់ផែលក្នុងទឹកថ្លា  ចង្វារផ្តោងផ្តក់ក្អុកគជ្រា ។
ស្លូតស្លាតសង្វាតហែលប្រែប្រើង  កែកែសច្រឡឹងច្រឡំគ្នា
ក្តាមខ្យងត្រសងតាមហ្វូងវា  ព្រលីតស្លាបទាលូតលលេច ។
ទូកសោតចែវស្រូតសសៀរឆ្លង  ហួសខេត្តជាម្តងលឿនស្រួលស្រេច
ទាវនឹកដល់ទុំមិនមានភ្លេច  រំពេចត្រូវខ្យល់ដល់កោះកុក ។
ចែវស្រូតទន្ទឹមពាមជីកង  កាត់ឆ្លងទៅកោះឫស្សីស្រុក
អាសូរទាវសល់ខ្វល់វិតក្ក  ពុំសុខក្រហាយក្នុងកាយេ ។
៥៧៥. ចែវដល់ព្រែកពោធិកងត្រណើង  រការកោងនឹងដល់ល្វាទេវ
ទាវសោតសញ្ជឹងគិតរិះរេ  គ្នាន់គ្នេររំពឹងរីងថៃថប់ ។
ដល់ព្រែកដំបងជ្រោយមេត្រី  ភូមិស្លាតារីភូមិមាន់ដប់
ហួសពាមតាឯកព្រែកប្រសព្វ  ចែវចប់ដល់កោះខ្សាច់កណ្តាល ។
ទាវទុក្ខក្រៀមក្រំជាំកាយា  ទឹកទំណាស់សាផ្លាប់ស្និទ្ធស្នាល
ស្រីប្រុសស្រើបស្រស់ស្រួលឈឺឆ្អាល  បណ្តាលឥតគិតដល់ប៉ុនល្អង ។
មិនមានអាសូរទ្រូងទាវសោះ  ខំចែវស្រូតកោះកាត់កៀនឆ្លង
បានដល់ព្រែកហ្លួងព្រែកបង្កង  ស្រូតឆ្លងកៀនឃ្លាំងជ្រោយចង្វា ។
ដល់ក្រុងភ្នំពេញដែនដីរាប  រសៀលទន់ទាបព្រះសុរិយា
ឡើងមើលទំនិញគ្រប់តាមផ្សារ  ត្រៀបត្រាចិនខ្មែរហែគឹកកង ។
៥៨០. ស្រេចចរចុះទូកចែវចេញទៅ  មិនហ៊ានឈប់នៅខ្លាចក្សត្រច្បង
ដល់ច្រាំងចជ្រេះព្រែកព្នៅឆ្លង  បំណងកាត់តាមពាមដូនស្តើង ។
ចែវដល់កោះស្បែកព្រែកកោះចិន  បាយឆ្អិនស៊ីស្រេចលីលាឡើង
មើលអស់ទំនិញល្អថ្កុំថ្កើង  ស្រីប្រុសឈ្មិតឆ្មើង[1] ចរចើងចរ ។
ទូកដល់កំពង់រង់រៀបខ្លួន  ប្រាប់ទាវនឹមនួនឆោមបវរ
ទាវចុះងូតទឹកជ្រះល្អះល្អ  ស្បៀកពាក់បង់កខ្លួនស័ក្តិសម ។

---

១. ច្បាប់ខ្លះថា ឆ្នាំឆ្មើង។





លង់លុះទេវទាបព្រះសុរិយា ទាវកើតទុក្ខានឹកដល់ទុំ
ទន់ទាបជិតជះរិះបាំងភ្នំ ស្រទំត្រជាក់ចរយាត្រា ។
ដើរតាមដោយធ្លាមាគ៌ាថែក ដល់បន្ទាយលង្វែកដូចចិន្តា
ជិតជើងរាជវាំងអង្គក្សត្រា មើលផ្សារគ្រាគ្រៀបរៀបរៀងរាយ ។
៥៨៥. ប្រាសាទប្រសើរលើជហ្វា នាគាដងក្តារសីមាលាយ
កំបោរបាយអភាគបន្ទាយ ស្រះស្រង់ទ្រង់ទ្រាយទូលាយធំ ។
រោងទ័ពរងទងទំនងស្រួល ទាវមើលអន់អួលវិយោគយំ
ឮសូរសព្ទភ្លេងលេងរងំ គងធំយំយាមតាមលំដាប់ ។
ដោយនូវសក្តាមហាក្សត្រ មិនស្ងាត់សៀងសូរអ៊ូអឹងអាប់
យើងឈប់បង្អង់រឿងរៀបរាប់ នឹងចាប់សំដែងតែងតទៅ ។
ថ្លែងថាទាវទុក្ខពុំសុខសោះ នឹកឡើងស្រណោះទុំដោយនូវ
យប់យូរស្ងប់ស្ងាត់បានស្មុះក្តៅ ព្រះពាយផាត់ត្រូវហើយប្រាណ ។
ទាវប្រះប្រាណប្រែបែរវិតក្ក នឹកដេកពុំលក់ទុក្ខគ្មានក្សាន្ត
ថាឱព្រះពាយផាយផាត់ប្រាណ សមខ្ញុំប្រមាណអស់បានទុំ ។
៥៩០. ទុក្ខបួនទៀតហើយទុំអើយអ្នក នៅលើដំណាក់ក៏ភ្លេចខ្ញុំ
ឥឡូវបួនមកជ្រកដេកយំ ក្រាលគ្រាំដំបៅក្តៅឱរា ។
ព្រឹកនេះគេនាំខ្ញុំទៅថ្វាយ ស្តេចគង់ដែនអាយលើសិរសា
ខ្លួនឯងជារាស្ត្រតើលោកណា មេត្តាដឹងទុក្ខជួបមូលទុំ ។
ព្រឹកព្រាងភ្លឺស្វាងពណ៌រស្មី ទាវស្រីថែថប់កើតទុក្ខធំ
ទឹកភ្នែកស្រក់ស្រោកវិយោគយំ ធ្ងន់ខ្លួនស្មើភ្នំលំលើ ។
ស្រោកស្រន់អន់ធូរយូរបន្តិច ដៃស្រាយបង្វេចនៅស្ពាក់ស្មើរ
មើលយល់ប្រដាប់សព្វសារពើ តែងស្លៀកពាក់ធ្វើលំអអង្គ ។
ស្លៀកពាក់ទាំងទុក្ខទាវនួនល្អង តែងស្រេចជាម្តងខំផ្ចិតផ្ចង់
លាបប្រេងផាត់ម្សៅពណ៌ផ្ទូរផង់ ត្រចះត្រចង់ដូចចន្ទ្រា ។
៥៩៥. រៀបរួចស្រេចស្រាប់ប្រដាប់ផង ចរចេញត្រសងចរលីលា



ចូលដល់ឡប់ឡៃក្បែរមាត់ទ្វារ រង់ចាំរាជាចុងរោងរម្យ ។
កាលអើយកាលនោះព្រះចមត្រៃ ក្សត្រថ្លៃស្តេចចេញចាកបន្ទំ
ស្នំស្និទ្ធទាសីស្រីក្រមុំ តូចធំគាល់អង្គព្រះជេដ្ឋា ។
ស្តេចចេញប្រថាប់នៅរោងធំ ចតុស្តម្ភបង្គំគាល់ក្សត្រា
ស្នំស្និទ្ធប្រកិតស្រីកញ្ញា គាល់អង្គមហាក្សត្រច្បាស់ច្បង ។
កាលអើយកាលនោះទាវស្រីថ្លៃ ពណ៌ស្រស់ប៉ប្រៃប្រឡូតហ្មង
នាំគ្នាយាត្រាទៅត្រសង គាល់អង្គក្សត្រច្បងស្តេចទ្រង់រិទ្ធិ ។
ដល់ហើយឱនកាយថ្វាយអភិវាទ ខ្លាចព្រះនរនាថក្រាបជួញជិត
សេនាបតីស្រីស្នំស្និទ្ធ បង្គំទូលពិតអង្គឥស្សរា ។
៦០០. ស្តេចទ្រង់បែរបៀងទៀងទតជាក់ យល់ទាវវរលក្ខណ៍សមកាយា
ត្រូវព្រះហឫទ័យមានឱង្ការ ថ្លែងថារូបទាវគួរអាល័យ ។
ស្តេចមានបន្ទូលស្រួលសួរថា នែអស់កញ្ញាមហេសីថ្លៃ
រូបទាវល្អហើយឬសង្ស័យ ដូងចែថាចុះខុសលើកលែង ។
មហេសីទូលថាល្អជាក់ស្បាន់ ប្រផូប្រផាន់គ្រចះចែង
សមជាមហេសីនៃស្តេចស្តែង ស្តេចថ្លែងអោយហៅទុំច្រៀងថ្វាយ។
ទុំឮសូរសៀងប្រឹងផ្ទៀងស្តាប់ ច្បាស់ហើយចូលឆាប់ឱនអង្គកាយ
លើកហត្ថរួចចាត់ចែងបរិយាយ ឃើញទាវនោមឆាយម្តាយនាំដល់ ។
ប្រថុយគ្មានគិតជីវិតប្រាណ ក្តៅដូចភ្លើងគ្រានជ្រប់ស្រងល់
ខ្លោចផ្សារឱរាំរឹតខ្វាយខ្វល់ ផ្ទញ់ផ្ទាល់មិនរអែងក្រែងចេស្តា។
៦០៥. ថាឱព្រះចមត្រៃថ្លៃអនេក ជាឯកភូមិភពគ្រប់លោកា
លោកិយដែនដីឋានមនុស្សា ខ្ញុំខ្លាចចេស្តាព្រះបារមី ។
ទ្រង់មានឱង្ការចាត់អោយរក អោយរើសរូបមកជាមហេសី
ឥឡូវបានទាវស្រស់ប្រិមប្រិយ មិនគួរគប្បីគាស់ទទឹង ។
ខ្លាចព្រះចេស្តាម្ចាស់ទ្រង់រិទ្ធិ ទូលបង្គំសូមពិតឯទាវហ្នឹង
ជាក់ជាសង្សារប្រាថ្នាពឹង សន្ទតិវិលវឹងគ្រប់ជាតិ ។

ជាតិតាំងកំណត់សន្ទត់កើត    យោនយកកំណើតជាប្រុសស្រី
អោយជួបទាវសួនទួនពិសី    ប្រាថ្នាកុំបីអោយឃ្លាឃ្លាត ។
ទាវស្តាប់សាសព្ទទុំច្រៀងថា    ក្តៅក្នុងឱរាតឹងចង្អៀត
មិនហ៊ានងើបមើលមុខទុំទៀត    ខ្លាចក្សត្រនរនាថយកទោសា ។
ទុំច្រៀងរៀបរាប់ដំណាលសព្ទ    តាំងពីទុំធ្លាប់រួមស្នេហា
ទាវសោគគ្រៀមក្រំអន់អួលផ្សា    ក្តួលក្តៅឱរាមិនមានស្តី ។
កាលនោះឯអង្គព្រះចមត្រៃ    ក្សត្រថ្លៃទ្រង់ខ្ញាល់នឹងទាវស្រី
ឈ្លេងគួរ[1] សន្តោសប្រោសប្រណី    ព្រះទ័យជញ្ជីងរំពឹងកាត់ ។
ទ្រង់ធម៌ថាអញ្ជយកទោសវា    សមនឹងឃ្លាតឃ្លាសង្សារសត្វ
ព្រះធម៌មេត្តានឹងបង់បាត់    គួរផាត់ទាត់ចោលចេញទើបជា ។
មានព្រះតម្រាសប្រាប់មន្ត្រី    អោយយកទាវស្រីមកសួរវា
បើឆ្លើយទៅហើយត្រូវពាក្យគ្នា    យើងលើកលែងវាតាមចម្លើយ ។
ស្តេចមានព្រះរាជឱង្ការ    បន្ទូលសួរថានែទុំអើយ
ទាវសង្សារមែនចូរឯងឆ្លើយ    កុំបិទបាំងឡើយប្រាប់តាមត្រង់ ។
កាលនោះទុំសោតខ្លាចបារមី    ផ្ទៀងស្តាប់ជាក់ខ្ពីលើកកផ្ទង់
ទុំទូលក្សត្រាដោយស្មោះត្រង់    សូមទានព្រះអង្គប្រោសប្រណី ។
ករុណាសម្លាប់តាមទោសធំ    ទុករស់ជាខ្ញុំព្រះបារមី
ទូលបង្គំជាខ្ញុំនឹងលាក់ថ្វី    ឯនាងទាវស្រីសង្សារពិត ។
ទ្រង់ត្រាស់សួរទៅនាងទាវវិញ    ទាវអើយខ្លួនមិញអញ្ជពិនិត្យ
ប្រាប់ដោយពិតត្រង់កុំភ័យភិត    បានរួមផ្គែកផ្គិតឬមុសា ។
ទាវទូលទៅអង្គព្រះចក្រី    បពិត្រនរបតីសូមមេត្តា
ខ្ញុំនិងទុំពិតទៀងសត្យា    ដូចព្រះករុណាទ្រង់ជ្រាបស្រាប់ ។
កាលនោះឯអង្គព្រះចមត្រៃ    ក្សត្រថ្លៃបានទ្រង់ព្រះសណ្តាប់

១. ច្បាប់ខ្លះថា តែឈ្លេង



ទ្រង់ឆ្លេងជឿជាក់ទាវសាសព្ទ    ស្តេចត្រាសប្រញប្តិ[1] ប្រាប់សេនា ។
ទ្រង់ព្រះតម្រាស់នឹងកុង្សីយ៍    មាត្យមុខមន្ត្រីខ្ញុំរាជការ
អោយរៀបប្រដាប់មង្គល់ការ    ក្សត្រានឹងផ្សំទាវនិងឯក ។
ចតុស្តម្ភបង្គំលាចក្រី    ទៅផ្ទះទីទៃវិញដោយឡែក
ប្រាប់គ្នាទៅមកថាថ្ងៃស្អែក    កុំចាំរារែករួសរៃៗ ។
ទើបក្រោកក្រាកចាកទែនមណី    យាងចូលមន្ទីរក្សាន្តព្រះទ័យ
ផ្ទំលើសយនាឋានប្រពៃ    ទុំគាត់គិតតែគាល់រាជា ។
លង់លុះព្រឹកព្រាងស្វាងឡើងជាក់    ក្សត្រថ្លៃទ្រង់លក្ខណ៍ចាកនិទ្រា
ចេញគង់ចុងរោងជុំស្រីង្គារ    មន្ត្រីរាល់គ្នាឡើងគាល់ក្សត្រ ។
ស្តេចទ្រង់បង្គាប់អោយរៀបចំ    នាំទាវមកផ្សំអោយឆាប់ថ្វាត់
ទុំទាវចូលគាល់ឱនប្រណិប័តន៍    មហាក្សត្រស្តេចអោយពរមង្គល ។
ជួបជុំបតីមន្ត្រីធំ    ចតុស្តម្ភមូលមកជួយរវល់
ផ្សំផ្គុំទុំទាវថ្លៃនិមល    ទសពលទ្រង់ក្សាន្តមានមេត្តា ។
សំពះចុងស្លឹកព្រឹកនោះស្រេច    បរិបូណ៌សួរចមង្គលការ
ម្តាយទាវគាត់លាអង្គក្សត្រា    នាំញាតិឡប់សាមកស្រុកវិញ ។
ឯទាវនួនលងល្អពិសី    បានរួមមេត្រីនឹងគ្នាមិញ
ទាវសោតបានសុខឥតទុក្ខម្នេញ    ពិតពេញដូចចិត្តគិតចេតនា ។
ទុំនៅយូរទៅក៏សុខសាន្ត    ឡើងគាល់ក្សត្រក្សាន្តអង្គឥស្សរា
នៅស្ថិតរួមស្ថានក្សាន្តចិន្តា    ឥតមានទុក្ខានឹងអ្វីឡើយ ។
ថ្លែងពីម្តាយទាវទៅដល់ស្រុក    វិតក្កព្រួយប្រាណពុំបានស្បើយ
ថាឱទាវថ្លៃកែវកូនអើយ    ម្តេចឡើយមកបានប្តីកំសត់ ។
ពីព្រោះអាចោរចិត្តចង្រៃ    កាចក្រៃវិស័យវាហ៊ានក្បត់
ថាទាវសង្សារវាប្រាកដ    ស្តេចអត់ពុំយកនូវទោសា ។

១. ប្រញប្តិ = បញ្ញត្តិ, បង្គាប់ ។

អញផ្តាច់ពង្រាត់ពីអានេះ មិនមានសន្ទិះគិតសង្កា
កិច្ចកលឧបាយតាមប្រាជ្ញា ផ្តាច់អាទុំចោរចិត្តទ្រុស្តក្បត់ ។
គិតផ្សំផ្គុំស្រេចនឹងម៉ឺនងួន កូនលោកអរជូនពិតប្រាកដ
អញអោយថ្វីអាទុំសាត់ព្រាត់ ពង្រាត់ចេញជាវេលាហ្នឹង ។
អញគិតអោយទៅលោកអរជូន ម៉ឺនងួនកូនគាត់គ្រាន់ទីពឹង
មានទ្រព្យស័ក្តិយសខ្ពស់ត្រដឹង តាមខឹងគិតខុសដល់យូរថ្ងៃ ។
កបពាររាត្រីស្រីម្តាយទាវ ខេខឹងឆុលឆាវគ្មានសំចៃ
សូវចង់បង់ទ្រព្យធ្លាប់ដល់ក្ស័យ តាមចិត្តអាល័យមិនមានគិត ។
៦៣៥. ស្រេចហើយម្តាយទាវចុះដើរទៅ ដល់ឡើងលំនៅធ្លាប់ស្ពាលស្និទ្ធ
ជន្លងនឹងគ្នាដោយទុកចិត្ត ជាមិត្តឥតមោះចោះថ្លាថ្លៃ ។
គាត់ដល់អង្គុយផ្ទង់ស្មារតី លើកដៃសំពះថាខ្ញុំឯង
ជាស្រីហាក់ដូចបានតុបតែង ខ្លាចក្រែងខុសសល់លោកមេត្តា ។
ក្តៅណាស់ចៅហ្វាយនឹងអាទុំ នាំអោយអាប់អោនកេរ្តិ៍មេបា
ព្រហើនមិនមានខ្លាចនរណា ឥឡូវខ្ញុំថាសូមចៅហ្វាយ ។
រិះរកធ្វើនុំផលចំណី ជ្រក់មាន់ទាត្រីស្រានូវបាយ
បន្លែគ្រប់មុខទុកពីអាយ បម្រុងចុតហ្វាយចាត់ដល់ទៅ ។
ទាវកូនអោយវិលមកប្រញាប់ ពាក្យពេចន៍សាស័ព្ទថាម្តាយនៅ
ឯនាយឈឺធ្ងន់គ្រុនចុកក្តៅ ផ្តាំមកកូនចៅសាច់សន្តាន ។
៦៤០. វិលឆាប់ទើបទាន់ម្តាយផ្តែផ្តាំ រង់ចាំរឹតខ្លាំងភាំងប្រមាណ
កម្លាំងតិចណាស់ខ្វះក្នុងប្រាណ ម្ល៉េះខានឃើញមុខជាទុក្ខធ្ងន់ ។
បើបានទាវកូនមកដល់ហើយ បង្អង់អ្វីឡើយរៀបកែកុន
កែគិតអោយងួនជាប្រពន្ធ យើងផ្សំពីមុននឹងគ្នាស្រាប់ ។
ម្តាយទាវវិលដល់ទីគ្រឹះស្ថាន គាត់គិតប្រមាណរួមប្រញាប់
រកស្តីគេធ្វើសំបុត្រឆាប់ រៀបគ្រប់ប្រដាប់ប្រាប់ប្រើទៅ ។
ចាត់អោយអ្នកនាំអង្គអក្ខរា គាត់ប្រាប់ផ្តាំថាកុំអង់នៅ
អោយយូរដំណើរត្បិតឥឡូវ ថាម្តាយឈឺក្តៅអត់ភោជនា ។
អ្នកទាំងអម្បាលកាលនោះមិញ ស្រុះស្រួលស្រឡាញ់ដូចចិន្តា
ចុះទូកចែវភ្លាមតាមជលសា ប្រាថ្នាបានដល់សាកលនាយ ។
៦៤៥. ចតទូករួចឡើងទៅរំពេច ដល់ផ្ទះទុំស្រេចសួររួសរាយ
ទាវថាម្តេចទៅអ្នកលោកម្តាយ សប្បាយសុខសាន្តឬមានអ្វី ?
អស់អ្នកទាំងឡាយពីអាយស្តាប់ ទាវសួររួចរាប់តាមសេចក្តី
ស្រាយយកសំបុត្រអោយទាវស្រី មើលដឹងទាវភ័យស្លុតភ័ន្តភាំង ។
ទាវថាឱអ្នកវរលក្ខណ៍ប្អូន ម្តាយខ្ញុំឈឺសូន្យស្មើរមរណំ
ថាអត់អាហារហេវស្គមស្គាំង ឥឡូវមានទាំងកំណត់ថា ។
អោយខ្ញុំលាអ្នកបងទៅឆាប់ រួសរាន់ប្រញាប់តាមសញ្ញា
អោយជុំកូនចៅញាតិកា សែនព្រេនមេបាខ្មោចក្នុងផ្ទះ ។
ទុំដកដង្ហើមធំថប់ថា ឱប្អូនសង្សារខំរូតរះ
ទៅហើយបើជាប្អូនរហ័ស កុំលះលន្លង់សុងយូរឡើយ ។
៦៥០. បងរៀបដំណើរអោយកល្យាណ ខ្លួនបងឈប់ខាននៅនេះឡើយ
ធុរៈរាជការក្សត្រត្រាណត្រើយ ប្អូនអើបប្រយ័ត្នអង្គអាត្មា ។
ទាវលាទុំចរចុះទូកស្រេច ចែវស្រូតរួចលេចជ្រោយចង្វា
ខំចែវមិនចតឈប់ឡើយណា ចិន្តាទាវទុក្ខមុខក្រៀមក្រំ ។
ទុក្ខមួយឃ្លាតប្តីថ្មីឯកា ទុក្ខមានមាតាឈឺដំណំ
ទាវថាឱអញម្ទេញចាកចំ បែងបង់បារម្ភក្រំច្រើនផ្លូវ ។
ចែវចប់ដល់ពាមភ្លាមដល់កោះ ស្រូតតាមចន្លោះមិនមានត្រូវ
គ្មានឈប់អង្គប្រាណសំរាន្តនៅ ចតឈប់ឡើងទៅដល់ត្បូងឃ្មុំ ។
ទាវឡើងលើផ្ទះដាក់កាយា យង់យល់មាតាមាមីងជុំ
សាច់ញាតិសង្ហាតមកជំនុំ រៀបភោជន៍ផលនំផ្សំស្រាបាយ ។
៦៥៥. ដៃចាប់បាននំអន្សមស្រា សែនថ្វាយដូនតាច្រូចថ្វាត់ថ្វាយ
ថាអស់ខ្មោចតាយាយនូវម្តាយ អញ្ជើញមកអាយសេពសោយផល ។

សោយស្រេចអោយពរមកកូនចៅ
សាច់ផៅប៉ុន្មានកុំអោយសល់
តឡប់ទាវកូនទើបមកដល់
ចូរកូនតម្កល់គិតវែងឆ្ងាយ ។

ទាវមកដល់ហើយកូនអើយស្ដាប់
ម្ដាយនឹងសាស័ព្ទបទបរិយាយ
ធម្មតាកូនកើតមានរូបកាយ
ល្ហល្ហះឆើតឆាយចាយសម្ដី ។

ញញោះចំពោះដល់មហាក្សត្រ
យកទៅថ្វាយថ្វាត់ទ្រង់ប្រណី
ប្រែអោយម៉ឺនឯកឥតមានអ្វី
ក្រក្រីធនធានគ្មានស៊ីសោះ ។

ហេតុនេះម្ដាយប្រែកែគិតផ្សេង
អរជូនសញ្ជើងគួរស្រណោះ
គេមានស័ក្តិបុណ្យធនរបស់
បណ្ដោះទាវទុកគ្រលុកការ ។

៦៦០. ផ្សំនឹងម៉ឺនងួនកូនគេមាន
ស័ក្តិយសធនធានតាមប្រាថ្នា
ខាងជើងទឹកទូកចែវចាក់ក្ការ
ចិត្តចង់ប្រាថ្នាក៏មានគ្រប់ ។

ដីរទេះសេះគោខ្មែរ
សិរីកាគ្រែបិទបាំងមូប់
មានភ្លេងល្មើយល្ងេងទាំងថ្ងៃយប់
ម៉្លេះហើយទាវថប់អ្វីស្រីម្ដាយ ។

ទាវស្លាប់ម្ដាយដាក់ស៊ើរធ្លាក់ថ្លើម
ហៀបផុតដង្ហើមក្ដួលក្ដៅកាយ
ថាឱព្រះមេមានគុណឆ្ងាយ
ម្ដេចប្រែកែក្លាយឃ្លាតធមិអាថិ ។

បើម៉ែកែអោយកូនមានប្ដី
ទំហឹងដូចក្ដីស្និទ្ធស្នេហា
នេះកូនក៏ព្រមលួមស្នេហា
ផ្ដុំប៉ផ្ដាល់រក្សាឃ្លាតទៅ ។

ថាបើម៉ែមិនមានមេត្តា
អោយខ្ញុំព្រមការម៉ឺនងួននៅ
សមក្ស័យជីវិតក្សិតមិនត្រូវ
អង្វរម៉ែឪសូមប្រកែក ។

៦៦៥. នាងម្ដាយសម្លក់សម្លឹងមុខ
កើតទុក្ខព្រោះកូនគិតអល់ឯក
ជេរថាមេចោររឹងដូចដែក
អញចាប់មាត់ហែកបែកឥឡូវ ។

អញប្រាប់អោយមានបានថ្កុំថ្កើង
ហ៊ានហួសចចើងស្ដីគ្មានត្រូវ
ស្រឡាញ់អាទុំគ្មានម៉ែឪ
គ្មានគិតអាស្រូវភាសខ្មាស់គេ ។

មិនស្គាល់គេមានរបស់ទ្រព្យ
បាងចង់ប្រសព្វអាឥតមេ
ឥតបាងណាកើតដល់កេរ្តិ៍
ចំណេរទៅលង់គង់តែក្រ ។

ទាវឮម្ដាយខឹងក្រញ៉ឹងខ្លាំង
ឆ្លើយឆ្លៀតតតាំងសូមអង្វរ



ម្ដាយស្មៀមស្ងាត់ចុះទៅស្មោះសរ
ចាកចរដើរដល់ឡើងត្រើះស្ថាន ។

ឧកញ៉ាអរជូនខ្លួនមានបុណ្យ
ឃើញហើយអរលន់ពន់ប្រមាណ
ថាអ្នកអញ្ជើញមកកំសាន្ត
ព្រួយប្រាណនឹងអ្វីអីដល់ខ្ញុំ ។

៦៧០. នាងជាជន្លងឆ្លងឆ្លើយថា
ចៅហ្វាយរៀបការអោយសុខុម
ជម្រាបអ្នកស្រីចាត់ធ្វើទំ
ហៅភ្ញៀវជួបជុំស្រេចជាម្ដង ។

យើងឈប់អង់សិនមិនសំដែង
ផ្កាថ្លែងទាវកើតទុក្ខសៅហ្មង
មិនឃ្លានអាហារភោជន៍ផលផង
ទុក្ខធ្ងន់កន្លងកន្លែងគិត ។

ប្រះប្រាណវិយោគសោកឡឹងឡង់
អញអើយម៉្លេះបង់ដល់ជីវិត
ក្សិណក្ស័យព្រោះឆ្ងាយទុំចេរចិត
គ្មានដឹងគំនិតគេខឹងខ្លាំង ។

ទៅបញ្ឆោតខ្ញុំមកមែនហើយ
ទុំអើយឥឡូវគេបង្កាំង
បង្អាន់បង់ប្រាណដល់មរណ៍
ខ្ញុំតាំងសច្ចាចិន្តាថ្វាត់ ។

ទាវទុក្ខបណ្ដើរធ្វើអក្ខរា
សរសេរស្រេចស្រីទាវប្រយ័ត្ន
បត់បិទរុំជិតនឹងស្លាថ្នាត់
បារីស្លឹកកាត់ចាត់បម្រើ ។

៦៧៥. មនុស្សដែលទាវទុកចិត្តស្និទ្ធស្នាល
ឈើឆ្កាលជាសាច់ញាតិប្រសើរ
ប្រសប់ដំណើងដឹងផ្លូវដើរ
រហ័សហាក់ហើរប្រើទៅខ្ចី ។

នាអ្នកច្បាស់ជាក់ទាវប្រើហើយ
មិនបង្អង់ឡើយនាំអក្ខរា
អក្ខរានិងស្លាថ្នាត់ថ្មី១
បារីទាវខ្ញុំប់សព្វឥតខ្វះ ។

ចរចុះចំពោះចេញលិលា
ដល់ដានមាគ៌ាភ្លែតរហ័ស
រហើយខ្លួនប្រាណបានរួតរះ
រួសរាន់ស្វែងស្វះប្រទះទឹក ។

រូបស្តីប្រុសស្រីនៅទន្លេ
ចម្លងទទេរគេគិតនឹក
អាណិតអ្នកមួយព្រួយពន្លឹក
ចុះទូកចូកទឹកចែវលឿនលន់ ។

លុះដល់សកលខេត្តដែនដង
សួរអស់អ្នកផងអ្នកអើយម-
ណ្ឌលទីទុំទាវមកផ្ដាប់ផ្ដូន
ថ្ងៃកែវមានបុណ្យជនចូលជិត ។

៦៨០. មូលមកពីងតេជបែកអំណាច
ប្រជាជនខ្លាចដោយសុចរិត
សត្រូវខ្ចាត់ឆ្ងាយមិនហ៊ានជិត
ខំប៉ះល្ពោចល្ពិតជីវិតគ្មាន ។

នាអ្នកចម្លងវិលដល់ផ្ទះ ស្រឡះរួចកែបែរនិទាន
បម្រើទាវទៅដល់មិនមាន បារម្ភពើបពានឈានដើរដល់ ។
ផ្ទះទុំទុកចិត្តស្និទ្ធស្នាលស្រាប់ ទុំឆាប់ស្រដីសួរគ្មានសល់
ថាមកសុខសាន្តឬកង្វល់ អ្វីគួរពិភាល់ឆ្ងល់សូមប្រាប់ ។
អ្នកទៅពីអាយស្រាយសំបុត្រ ទុំមើលស្រយុតដៃយោងចាប់
ស្រាយមើលឃើញស្លាមានជន្លាប់ ប្រដាប់បារីស្រីបងផ្ញើ ។
ឱ! ទាវទួនលួងបងកើតទុក្ខ ឆ្ងល់ឆ្ងែតណែនចុកទៀតហើយតើ
រីតរឹងព្រលឹងបងចាត់ប្រើ ដំណើរដូចដឹងឬរឿងទៀត ។
៦៨៥. ឱ! ទាវអើយទៅពីព្រោះម្តាយ មិនដឹងប្រែក្លាយមានប្រើស្មៀត
ទាវអើយទុក្ខធំចង្អៀត ស្តាត់ស្មៀតដូចភ្នំរលំលើ ។
ទាវអើយទាវស្រីប្រណីបង មែនពិតជាម្តងទើបហ៊ានធ្វើ
អក្ខុំទាវស្រីប្អូនចាត់ប្រើ ដំណឹងដំណើរអោយឆាប់ដល់ ។
ប្អូនអើយទុក្ខបងម្តងហ្អឹងធ្ងន់ ពេញពៀបទូរទន់សូន្យស្រងល់
ស្រងាត់ដូចហាក់អកុសល ខ្វាយខ្វល់ឡើនឡង់អង្គរាយមាយ ។
ទាវអើយប្រសិនខ្លួនបានគេ បងនៅទេទេមិនឈប់ងាយ
ស៊ូបង់ជីវិតដូចសឹងនាយ ស្លាប់ក្នុងបន្ទាយចំណោមធំ ។
ធម្មតារាជការមេកងសឹក មិនមានភ្លូកភ្លឹកស៊ូរលំ
គេបាញ់គេចាក់គេផាក់ច្រំ នេះសមស៊ូប្តូរផ្តាច់ជន្មា ។
៦៩០. ថាអោយបងឈប់មិនឈប់ឡើយ ទាវថ្លៃប្អូនអើយបើមរណា
ស្លាប់យកជាតិទៀតទៅក៏ជា ច្បាំងដូចមារាវេលាហ្អឹង ។
ទុំទុក្ខមុខគួរតែសង្វេគ ទុក្ខទាវបាក់បែកក៏ស្ងាត់ឈឹង
វិយោគយល់ស្ងាត់បាត់ព្រលឹង ប្រះប្រាណស្តុកស្ដឹងលើផែនទី ។
ដំណេកធ្លាប់ដេកនៅនេះហើយ ទាវថ្លៃបងអើយធ្លាប់ពេលស៊ី
ភោជន៍ផលចំណីស្រីឃ្លាតពី បង់បោះចាកនិវាសប្រាសឆ្ងាយ ។
សង្សឹមម្តាយស្រីចង្រៃធំ គាត់នាំបំបែកអោយខ្វាត់ខ្វាយ



រកកលសម្លាប់បង់អន្តរាយ ទាវអោយសមស្រស់អស់បានយល់ ។
ទុំយល់ប្រដាប់ជន្លាប់ស្លា ហួលព្រៃក្រមាពូកខ្នើយខ្ពល់
កន្ទេលចៀមធំក្រំទុពិល ឃើញហើយសសុលក្រុងក្រាបលក់ ។
៦៩៥. ក្រោកក្រេកប្រវាលូកហត្ថឈោង កៀនគើយត្រកងក្រហាយចុក
ផ្អែកឆ្ងល់ខ្វល់ចិត្តរីតវិតក្ក ពុំសុខក្រោកក្រាកចាកចេញចរ ។
ចុះដីរឹងមើលអាកាស ស្រឡះស្រឡេតល្ហេតស្លុតកក
ស្ងាត់កាន់តែយប់ជុំប់ត្រដរ រាប់រៀបតំណៀបទៅព្រឹក ។
ថាឱព្រះពាយផាយផាត់ជូន ពពកពពូនទាវប្អូនទឹក
វិខ្លួនស្ងួនខ្វាត់បាត់រលឹក ទាវអើយបងផឹកទឹកតាងបាយ ។
ទុក្ខបងដូចដល់ស្រងល់ងោង ផងផោងប្រៀបដូចកូននឹងម្តាយ
ប្រាសស្លាប់ទៅវាមិនយល់កាយ បងប្រាសទាវឆ្ងាយឃ្លាតឃ្លាខ្លួន ។
ឃ្លាតសព្វដំណេកដេកទំនេទី គ្រឿងស៊ីគ្រឿងតែងប្រេងក្រមួន
ក្រមិនយល់សោះអស់ជួបជួន ទាវស្រីជ្រកពូនងួនជាប្តី ។
៧០០. ថាបើទាវបានទៅងួនពិត ស៊ូប្តូរជីវិតព្រោះប្អូនស្រី
គេយកពីទ្រូងទៅថ្មីៗ គ្មានគិតប្រណីភ័យប៉ុនល្អង ។
ម៉ឺនឯកសង្វេគបែកទាវស្រី លុះព្រឹកព្រៀងខ្ទីបីត្រកង
ចាប់នេះចាប់នោះរបស់ផង ទុកដាក់ជាម្លងបងយាត្រា ។
ចរចុះដើរដល់វាំងមហាក្សត្រ ចូលកាត់ទុំគ្មានខ្វាចនរណា
ដល់ដាក់អង្គគាល់ផ្គាល់ព្រះមហា- ក្សត្រទ្រង់ចេស្តាបុណ្យបារមី ។
ទុំលើកហត្ថប្រែប្រញ្ញប្រុង ផ្គុំផ្គងបំរុងទុកសិរសី
ទុំថាទូលបង្គំជាខ្ញុំស្រី ចេញទៅមានប្តីថ្មីស្រឡះ ។
តាមទ្រង់ចមចេរមេត្តាប្រោស ទោសានុទោសទុក្ខធ្ងន់ណាស់
ករុណាសូមសុំព្រះអម្ចាស់ ចាត់ឱង្ការត្រាស់ទ្រង់ដល់ទៅ ។
៧០៥. ឧកញ៉ាអរជូនខេត្តត្បូងឃ្មុំ ខ្លួនលោកជាធំឈរនិត្យនៅ
សំបុត្រថាម្តាយទាវឈឺក្តៅ ផ្តាំអោយកូនចៅផៅសន្តាន ។

ទាវទៅទុកការនឹងម៉ឺនងួន
ទាវស្រីភ័យខ្លួនមិនហ៊ានខាន
ចាត់នាំកំណត់មកបើបាន
បន្ទូលទៅថ្កានឆាប់ទើបទាន់ ។
ស្តេចទ្រង់សន្តាប់សព្វវាចា
ទ្រង់មានឱង្ការត្រាស់រួសរាន់
អាចោរអរជូនដូចពងមាន់
វាភ័ន្តហ៊ានភព្វនឹងម្លប់ពោធិ ។
មិនដឹងខុសត្រូវស្រូវស្រងែ
អាចោរដូចឆ្កែស៊ីសាច់គោ
វាហ៊ានទទឹងទោសត្រូវស្មោរ
អញស្រាវរាវរកស្មោរខ្ទះដែក ។
អាចោរពូនព្រៃរំពៃព្រេច
ធ្លាប់ចៀសវះគេចដូចសត្វខ្ទែក
អាស្វាមិនស្គាល់ព្រនង់បែក
ក្បាលវាស្អែក។សង្វេគទៅ ។
៧១០. កាលអើយកាលនោះព្រះរាមរាជ
ទ្រង់ព្រះអំណាចក្រោធក្រឡៅ
ទ្រង់មានតម្រាស់ត្រាស់អោយហៅ
ថាចូរអស់ចៅក្រមសាលា ។
នាម៉ឺនមាត្យមុខមន្ត្រីធំ
ពួហើយចូលជុំមកស្តាប់ការណ៍
គាល់ព្រះមហាក្សត្រឱនសិរសា
ក្រួញក្រាបហត្ថាដាក់សិរសី ។
ស្តេចទ្រង់ទតទៀតទៅនឹងក្រុម
នាម៉ឺនតូចធំមុខមន្ត្រី
ត្រាស់ថាចតុស្តម្ភក្រុមកុង្សីយ៍
ចាត់ចែងសេចក្តីបន្ទូលឆាប់ ។
អាណិតម៉ឺនឯកបែកប្រពន្ធ
ថាម្តាយឈីធ្ងន់គេមកប្រាប់
ទាវទៅដល់ក្នុងវង់កណ្តាប់-
ដៃអរជូនចាប់ប្រញាប់ការ ។
ផ្សំនិងម៉ឺនងួនកូនវាពិត
វាហ៊ានមិនស្និតខ្លាចនរណា
អញផ្សំអោយឯកព្រោះត្បិតថា
ទាវជាសង្សារវាប្រាកដ ។
៧១៥. ឯទុំបើបានបន្ទូលទៅ
រួសរាន់អោយត្រូវតាមសន្ធត
បើវាមិនស្តាប់ឯងឆាប់បត់
វិលមកឈប់អត់អោយមើលវា ។
មន្ត្រីបានស្តាប់បន្ទូលថ្លៃ
លើកដៃបង្គំរៀងរាល់គ្នា
ថយមកដល់ក្រៅវាំងរាជា
រួសរ៉ាឈប់ទ្រឹងគឹងអាល័ក្សណ៍ ។
ជំនុំចាត់យកក្រដាសឯក
ប៉ាកកែចម្លែកធ្វើនឹងប្រាក់
សរសេររួចចូលទៅដល់ថ្នាក់
ចាត់ចាក់យកត្រាសង្ហារធំ ។
បោះបត់ជាផ្គត់បិទជិតជាប់
ទទួលគំនាប់បានហើយរុំ



សំពត់ព្រៃសូត្រឈ្នួតផាហ៊ុម
ស្រេចទុំជំនុំនិងពេជ្រថា ។
ពេជ្រអើយទុក្ខបងម្តងហ្នឹងធ្ងន់
ប្រពន្ធគេយកទៅរៀបការ
ចូរពេជ្ររួសឆាប់ប្រញាប់ណាំ
រករៀបទូកក្តារច្រវាចែវ ។
៧២០. នូវគ្រឿងស៊ីសព្វប្រអប់ស្លា
ក្រមាហូលព្រៃដបតែកែវ
បម្រុងទាញទូកមកខាងចែវ
ហៅក្រុមយើងចែវចេញឥឡូវ ។
ទុំចរចាកចុះដល់ទូកស្រេច
ចែវចេញលយលេចលឿនដោយត្រូវ
ព្រះពាយផាត់ជូនទុំសូន្យនៅ
ក្នុងទូកត្រហៅក្តៅខ្លោចផ្សា ។
ទ្រាំទ្រមិនបានប្រាណប្រះប្រែ
យល់ផ្កាយជិតខែហែទុំថា
ឱអង្គព្រះច័ន្ទជុំតារា
ទ្រង់ប្រោសករុណារំដោះទុក្ខ ។
ព្រះច័ន្ទចែងចាំងទែងរស្មី
ដូចពណ៌ទាវស្រីមិនយល់មុខ
ទុំរាប់រៀបរៀងច្រៀងទំនុក
មើលស្រុកមើលស្រីមើលត្រីត្រែង ។
ឱឈើជិតជូរគួរអ្វីអញ
ប្រាសទាវសម្លាញ់ម្នេញចំបែង
មិនដូចដើមត្រស់ក្រកោះតៀ្បង
ដូចស្លែងដុះស្លាប់ជាក់ជិតព្រៃ ។
៧២៥. ទុំរាប់ដើមឈើបណ្តើរទៅ
មើលយល់ទឹកជ្រៅឃើញហ្វូងត្រី
ចង្វាភ្លៀងផ្គងលោតឡើងខ្ចី
ខ្លួនអើយគួរបីបែកចែកឋាន ។
ចាកចរចេញជៀតឆ្វៀតរកប្តី
មានដូចហ្វូងត្រីក្នុងជលសា
មិនបែកគូគត់រត់ទៅបាន
ហ្វូងវាប៉ុន្មានក្សាន្តសប្បាយ ។
មើលស្រុកគេគាប់រាប់តម្រូវ
ត្រើយខាងកើតកូវផ្កាប់រាប់រាយ
ភូមិច្បារអំពៅនូវក្បៀនស្វាយ
ទុំសោតក្រហាយក្នុងកាយំ ។
ដល់យប់យូរយន់ពន់ពេកស្ងាត់
ព្រះពាយបក់ផាត់ត្រជាក់ខ្លាំង
ទុំទាញសំពត់គ្របបិទបាំង
ភាន់ភាំងក្រោកក្រេសរិះរឹតរឹង ។
កង្វល់ក្នុងប្រាណមិនបានល្ហែ
ព្រួយណាស់គិតតែដេកសន្ទឹង
ស្រែកព្រាវថាទាវថ្លៃព្រលឹង
បូនប្រាសសូន្យឈឹងនឹងបងទៅ ។
៧៣០. បងដល់សកលដែនអាយហើយ
ទាវអើយបានគេឬបូនទៅ
ធ្វើម្តេចអោយស្រេចដឹងឥឡូវ
មានស្លាបហោះទៅអោយឆាប់ដល់ ។

ចែវកាត់ច្រូតឆ្លងបំណងនឹង    ទុំរិះដញ្ជឹងប្រឹងចាំស្ដាប់
សូរខ្យល់រលកទូកស្ទើរផ្កាប់    ទុំសាប់សង្សារថាឱកម្ម ។
រូបកើតអភ័ព្វងាប់ទៅជា    នៅរស់វេទនាជាចំណាំ
ចំណែកបែកទាវស្រីស្រងាំ    ស្រងាត់ខ្វាត់នាំអោយវេទនា ។
ទុំរៀបរាប់ភូមិតាមទន្លេ    ហូរហៃផ្សៀងផ្សេរថាឱល្វា-
ទេរតោងកបកោងនៅរកគ្នា    ឈើចេះភ្ជាក់ងារមិនឃ្លាឃ្លាត ។
ចេះម្លេះប្របេះប្របៀតបាន    ដូចសាច់សន្ដានព្រៀនលានញាតិ
រការកគិតគំនិតមារយាទ    ឈើនិងធម្មជាតិចេះជាងគេ ។
៧៣៥. មិនដូចអរជូនខ្លួនជាមនុស្ស    មានបុណ្យស័ក្តិយសខ្ពស់ចំណេរ
គ្មានគិតលិចលង់ក្នុងនិរយេ    ចំណង់ចង់ចេរមិនថេរនៅ ។
ទុំរាប់ផ្កាប់ផ្គន់ចង់ចែវចាត់    មើលទឹកស្រងាត់ស្រងោចជ្រៅ
មើលត្រើយខាងជើងត្រណើងស្ទៅ    ឆ្លងកាត់សំដៅផ្ទះកណ្ដាល ។
ខាងក្រោយចុងបឹងប្រឹងឃ្មាតខ្មី    ទន្ទឹមឫស្សីស្រុកស្រើបស្រាល
ចាស់ក្មេងកំប្លែងលេងដំណាល    ត្រអាលសាកសួរមិនជូឆ្អើង ។
ថាអ្នកចែវទូកចូកប្រញាយ    អ្នកថ្លៃឆោមឆាយខំចែវឡើង
ហាក់ដូចរួសរាន់ទាន់ខ្យល់ប៉ើង    ចចើងចង់ឆាប់ប្រាប់ខ្ញុំផង ។
អ្នកសួរគួរដែរតែមិនស្ដី    ព្រោះទុំឃ្មាតខ្មីដោយមួហ្មង
មួយខំចែវច្រូតរូតនឹងឆ្លង    ត្រូវពាមជីកងបំណងនឹង ។
៧៤០. ចែវកាត់កោះកុកគោះសុទិន    បាយឆ្អិនឈប់ទូកគិតសញ្ជឹង
បានបោះបង្គោលចូលឈប់ទ្រឹង    រំពឹងសុរិយេក៏ទេរទៅ ។
បង់បាត់រស្មីព្រះសុរិយំ    ទុំភាំងទន់ខ្លួនជូនយប់ជ្រៅ
រួចបាយក្រហាយក្រហល់នៅ    ដោយត្រូវត្រជាក់ធ្លាក់ជំនោរ ។
ទុំស្រែកថាឱព្រះពាយផាត់    ទាវអើយបែកបាត់ផុំពិដោរ
ជាប់តែក្លិនក្លែបអែបគន្ធ-    រសរូបទាវចោរចើកចោលប្ដី ។
អោយនៅតែឯងតែអញសោះ    ទាវគ្មានស្រណោះគោតចិត្តស្រី



ចិត្តស្រស់ឥតធ្យានគ្មានប្រណី    បានងូនជាប្ដីមិនខ្វីទុំ ។
ឱ! ទាវអើយទុក្ខបងចំលែក    បងឡើងដល់ស្អែកទីត្បូងឃុំ
ម្លេះសមអរជូនគេគិតគុំ    ហៅក្មេរជួបជុំសម្លាប់បង ។
៧៤៥. ស្លេះឈប់អង់សិនមិនសំដែង    នឹងចាប់ចារចែងទាវសៅហ្មង
ជាទុក្ខរិតខ្លាំងភាំងម្តងៗ    ទាវផ្សងប្រាថ្នាតែប្រុសថ្លៃ ។
ប្រុសធ្លាប់ផ្កាប់ប្អូនខ្លួនមូលមិត្រ    ឥឡូវគេគិតគ្មានសំចៃ
សមចាកព្រាត់ប្រាសគ្នាពីថ្លៃ    ប្រាសរស់ឬក្ស័យអ្នកថ្លៃប្អូន ។
ប្រុសថ្លៃមកហើយឬអ្នកនៅ    ទន្ទឹងមើលផ្លូវបាត់ឈឹងសូន្យ
រំពឹងអ្នកម្ដាយកំចាយកូន    មិនដោយដំបូនដំបន់គ្មាន ។
គាត់អាងអោយគេមានយសស័ក្តិ    កែវកងមាសប្រាក់ទ្រព្យធនធាន
ទុំអើយខ្លួនអ្នកខ្សត់មិនមាន    ម្លេះសមមិនហ៊ានរុករានមក ។
ទើបបានប្រុសបាត់ឈឹងជ្រងំ    ទុក្ខប្អូនស្មើភ្នំយំក្រំក្រោក
ទៅណាមិនដល់ខ្វល់ជ្រុលជ្រក    ប្អូននៅនឹកភ្នកគ្រប់វេលា ។
៧៥០. ធ្វើម្ដេចបានដឹងជាយូរឆាប់    គ្មានគេទៅប្រាប់ឆាប់ម្ចីម្នា
នឹងបានជួបជុំលយល់មុខគ្នា    សោះប្អូនវេទនាជាទុក្ខខ្លាំង ។
ឥឡូវគេគិតមកឆាប់ៗ    រៀបប្រុងប្រដាប់ផ្គង់សម្រាំង
សម្រេចគេចូលមូលមានទាំង    ឈ្មួលមហាទីតាំងបង្ខាំងទុក ។
យើងអង់ស្លេះសិនមិនសំដែង    ទាវទុក្ខម្នាក់ឯងមិនមានសុខ
ថ្លាថ្លែងសម្ដែងតទៅមុខ    ម្ដាយទាវអផ្សុកវិតក្កប្រាណ ។
ព្រួយព្រោះនៅយូរគួរគិតដល់    ក្រហាយក្រហល់មិនបានក្សាន្ត
គាត់គិតចរចុះដើរទៅថ្កាន    ដល់ឡើងលើឋានដានលំនៅ ។
ផ្ទះអរជូនជុំប្រពន្ធកូន    ម្ដាយទាវមិនសូន្យជំរាបទៅ
លើកហត្ថាផ្គុំផ្គងតម្រូវ    ថាសូមឥឡូវខ្ញុំមកដល់ ។
៧៥៥. មិនគិតខ្មាសគេចំណោរលង់    ទោះបីខ្មៅល្ងង់តាមបន្ទាល់
ជំរាបចៅហ្វាយមិនអោយសល់    ងឿងឆ្ងល់ក្នុងគ្រាវេលាហ្នឹង ។

ទាន់ពារពេលាជាមង្គល ស្រេចលោកឈ្វេងយល់ក្នុងរំពឹង
មាននៅលោកស្រាប់ឆាប់ព្រួយប្រឹង ចៅហ្វាយតឿនតឹងទើបទាន់ចិត្ត ។
មើលពារពេលាខែថ្ងៃណា ជួបជុំមេបាដោយសុចរិត
មង្គលការនេះរិះអោយល្អិត ព្រោះត្បិតយូរខានមិនបានទេ ។
ទុកចិត្តម្តេចទុំបារម្ភទៅ ដោយក្តៅព្រោះហេតុប្រពន្ធគេ
ខ្ញុំសូមជំរាបលាវិលវេ រិះរេចាត់ចែងក្រែងក្រក្រោយ ។
វេលាគ្រានោះឯអរជូន លំឱនអរអឹងប្រឹងបណ្តោយ
ប្រាមប្រាប់ប្រពន្ធកូនថាអោយ កុំធ្លោយប្រហែសធ្វេសរាល់គ្នា ។
៧៦០. ប្រាប់ស្នងបាឡាត់ចាត់មេស្រុក រកជ្រូកព្រៃកុកគោមាន់ទា
ផែប៉ូវខ្ចីមម្រេចជំឡូងផ្កា គ្រឿងភ្លាផ្ទីផ្ទីជីបារាំង ។
គ្រឿងទេសគ្រឿងតែងបន្លែគ្រប់ ទុកមនុស្សប្រុសពួទិញស្រាខ្លាំង
សាច់ក្រកសាបក្រៀមសាច់ចៀមអាំង បំបែលត្រពាំងក្រសាំងខ្យង ។
គ្រប់ម្ទេសស្លឹកគ្រៃខ្ទឹរំដេង ក្រអៅរលីងឈូកសម្រង
ស្លែក្តោបស្លែលាភ្លាអង្រ្កង បង្កងស្នងគោនួវខ្ទុរល្ហុង ។
បន្លែចិតចាក់ចែកអោយរក បានមកច្រកជាលហាមបំរុង
ស្ងួតស្រួលប្រមូលច្រកការុង កុំអង់ឃឹតយូរគួរគិតឆាប់ ។
ខ្លះនាំឈើព្រៃឫស្សីផ្តៅ កាំបិតពូថៅខ្វិតដង្កាប់
យកទៅធ្វើរោងប្រុងប្រញាប់ ចាត់ប្រាប់ព្រៀងលានសន្តានឆ្ងាយ ។
៧៦៥. ក្នុងខេត្តប៉ុន្មានបានដឹងផង ត្បិតអ្នកជន្លងគាត់រាប់រាយ
ថារៀបអាងូនទាវឆើតឆាយ ខ្វល់ខ្វាយរស់រាន់ទាន់វេលា ។
ចាត់រកអាចារ្យខ្មែរធ្វើធ្មេញ អាចារ្យមួយដេញថ្ងៃជោគជា
ឫក្សរូមខ្មែយខ្វល់ដឹកលំពារ រូបរូមមូលគ្នាជាយូរទៅ ។
មនុស្សផងអឹងកងភ័យទោស រកទិញរកឈ្មួសគ្រប់គ្រឿងគ្រៅ
បានស្រេចនាំស្រូតរូតដោយនូវ អរជូនតម្រូវតម្រេកគេ ។
រត់ឡើងប្តឹងថាមេត្តាអត់ ទុកទោសកំណត់មិនធ្វេសធ្វេ



ចាត់ប្រើយើងខ្ញុំក្រុមដោយមេ ដោយមុខគិតត្រេះគិតគ្នាសែង ។
យកដល់ទៅទុករោងចុងភៅ ប្រដាប់ណាត្រូវតាមតុបតែង
បម្រុងរៀបស៊ីស្លាកន្សែង ចាត់ចែងចែកចាំរចាំភ្លេង ។
៧៧០. នាំទៅគ្រប់គ្រឿងរឿងទាំងឡាយ ចែកចាយទ្រទ្រាំកុំនាំលេង
រោងមួយធួនធំមាំល្ងឹងល្វេង ម្តៃប្រាំល្វែងតែងផ្កាលា ។
អុជអស់ប្រទីបគោមរយ៉ា មេបាព្រៀងលានសម្លាញ់ភ្ញា
ចរចូលមិត្រមូលជួបជុំគ្នា ក្នុងគ្រានោះឯងមិនក្រែងក្រ ។
ទើបតែជួបជុំចូលរោងថ្មី ប្រុសស្រីចាស់ក្មេងលេងអែបអរ
ស៊ីនំស៊ីបាយស៊ីសម្ល ស៊ីខស៊ីហុងវង់ផឹកស្រា ។
ចាស់ៗប្រុសស្រីស្តីរកគ្នា ថាយើងពេលពារវេលាណា
ឡើងចុះចំពោះលើលោកមហា ពិសារួចរាប់បង្គាប់មក ។
ចៅមហាអាចារ្យចេះគន់គិត ពិនិត្យថាយើងនឹងរិះរក
ពារពេញថ្ងៃស្អែករួចរៀបស្លក ឡើងយកកំណត់ប្រាកដហើយ ។
៧៧៥. រៀបរួចស្រេចស្រាប់បង្គាប់គ្នា អាចារ្យចោទនាឆ្លងឆ្លាស់ឆ្លើយ
មេបាខាងលើពុំលង់ឡើយ រួមខ្មើយថ្ងៃណាអាចារ្យចែង ។
អាចារ្យដើមការឯខាងប្រុស ពីកាលគ្រានោះគាត់សម្តែង
ថាអោយរៀបគ្រឿងគ្រប់តុបតែង តំណែងទំនៀមមិនស្មៀមស្ងាត់ ។
មានរានពេលាជាមង្គល បាយសីស្លាធមិស្លាប្រាំម៉ាត់
សំពត់ឆ្វេងស្តាំចាំប្រណិប័តន៍ ប្រយ័ត្នថ្លោះធ្លោយអោយមនុស្សចាំ ។
នោះត្រូវចាត់អាចារ្យពេលា ខាងលើគ្រីហាតាមចំណាំ
អាចារ្យខ្មែរខ្មុកសសុកគ្រាំ មានក្អមដាក់ថ្នាំផ្តាំអោយរក ។
បង្គាប់ថាត្រូវរកស្រូវកញ្ចើ ឯគ្រឿងខាងធ្វើធ្មេញអោយយក
ចន្ទន៍សក្រហមសសំបក ឆ្លូកឆ្លូកផ្លែកគ្នាជាច្រើនមុខ ។
៧៨០. បុកបត់កញ្ចប់កប់អង្ករ ច្រកក្នុងពកថ្វសួចាកចុក
ក្នុងក្អមមានចបជីកសសុក ផ្កាប់មុខពីលើទើជើងគ្រាន ។

ប្រដាប់ធ្វើភានមានរាជវិតិ ឆ័ត្រទង់បែងបត់ដោយប្រមាណ
បាយស៊ីចំណើដាក់តុបាន រៀបបានសព្វគ្រប់ឈប់ស្ទេះនៅ ។
ទើបនឹងបែរបត់ប្រាកដថា និយាយរឿងការទុកតទៅ
សម្តែងពីទុំសម្ងំក្តៅ ក្នុងទ្រូងដំបៅហៅពេជ្រថា ។
ពេជ្រអើយអង្គអញប្រុងប្រឹងស្លាប់ ឮដូចសូរស័ព្ទស្គរគេការ
ទាវងួនហើយថាឈប់ដល់ណា រៀបចតទូកក្តារយុថ្កាបោះ ។
ទុំពេជ្រលេចឮស្គរទៅដល់ កើតទុក្ខស្រងល់មិនស្បើយសោះ
ទឹកភ្នែករហែងរេងស្រណោះ ថ្លែងថាឱអស់សណ្ដានអាយ ។
៧៨៥. គ្មានគិតទ្រូងទុំក្រស្មើរបែក ខ្លួនអើយថ្ងៃស្អែកសមអន្តរាយ
បង់ខ្លួននឹងទាវថ្លៃឆោមឆាយ ទាវអោយគ្មានស្តាយទុំដល់តិច ។
ទុក្ខអើយពុំស្បើយដល់ប៉ុនល្ហង ទុំថាមាសបងយកបង្វេច
ម្ល៉េះហើយពេជ្រអើយនឹងធ្វើម្តេច ប្រថុយតាមកិច្ចតាមកម្មខ្ញុំ ។
ទុំស្រាយបង្វេចយកសំពត់ ស្លៀកពាក់រនត់ស្រេចស្រែកយំ
ដៃគរគក់ទ្រូងដៅងាលងំ ក្រេវក្រវិរយោគសោយសោកា ។
ពេជ្រប្រាប់ថាទុំកុំយំសោក ចូរបងប្រឹងក្រោកខំកំឡា
ស្លៀកពាក់ប្រដាប់អង្គអាត្មា ឆាប់ណាំអ្នកណាំកុំអង់នៅ ។
ទុំឮពេជ្រប្រាប់ចាប់សំពត់ ហួលព្រៃទាំងផ្គត់ទុំមើលទៅ
យល់ឈ្នួតជាហ៊ុមសូត្រពណ៌ខ្មៅ សំពត់ព្រះចៅប្រោសប្រទាន ។
៧៩០. ទុំស្លៀកហួលចាក់ជរបីជាន់ រូបមាន់សូត្រខ្សែស្រយមាសមាន
ពាក់អាវបៃតងបំណងធ្យាន ឈោងឈានបត់បែរប្រែស្រដី ។
ថាពេជ្រប្អូនអើយរៀបប្រដាប់ អោយស្រេចឆាប់ៗពេជ្រយកប៉ិ
យកចិញ្ចៀនបងទើបទិញថ្មី ទុំពាក់ម្រាមដៃត្បូងសូរ្យកាន្ត ។
ពេជ្រស្លៀកចរបាប់ចាប់អាវស្វាយ ពាក់ដើរកែក្រោយទាំងពីរប្រាណ
ចរចេរលើលាយាត្រាបាន ដល់ក្នុងស្មសានប្រមាណពេល ។
ពេលាថ្ងៃនោះឆ្ពោះប្រាកដ ពេលស៊ីកំណត់ក្រាលកន្ទេល



កំពុងផឹកស៊ីដេកនទេល ទ្រហែលរាល់ខ្លួនរត់ពួនព្រៃ ។
គ្មានដឹងខ្លួនសោះគេកោះកាប់ បង់ខ្លួនទាល់ស្លាប់មិនគិតភ័យ
អាត់តែស៊ីផឹកដូលទិទៃ ខ្លះវៃរត់ឆាប់ចាប់សាច់គោ ។
៧៩៥. អ្នកធ្វើឈ្នួលមយាការប៉ុន្មាន សប្បាយរាល់ប្រាណសើចចៀវឆោ
ធ្វើសាច់សាភ្លាមាន់ទាស្ងោរ ស្រែសកោកោះវះថ្លើមសួតសព្វ ។
ដំណើរទុំពេជ្រលេចពីព្រៃ គ្មានគិតភិតភ័យចូរបន្ទប់
បន្ទំមនុស្សច្រើនទ្រង់ចំប្រប់ គ្មានថប់ព្រួយចិត្តឥតព្រឺប្រាណ ។
ជាកម្មអកុសលផ្តល់គាត់ហើយ ជនអើយចូរស្តាប់ចាប់ចាំបាន
យកទុក្ខដាក់ខ្លួនពួនចេញឋាន ចៀសសង្ស្ការសាន្តខានឃើញទុក្ខ ។
គួរយកធមិអាចិជាទីពឹង ពំនឹងសីលទានស្ពានទៅមុខ
សូសៀវចៀសចាកផុតនរក កុំធ្វើឆោតឆតឆៅខ្មៅល្ងង់ ។
កុំយកតម្រាប់គាត់ពេជ្រទុំ នៅទីត្បូងឃ្មុំអ្នកលេងផង
លេងភ័ព្តស្រីទាវល្អមានទ្រង់ លិចលង់លុះបានប្រាណមរណា ។
៨០០. គ្រានោះនាអ្នកទាំងពីរប្រាណ ចូលដល់ប្រមាណពេលវេលា
សិរិយេទេវទាបប្រហែលជា ភ្ញៀវមកជុំគ្នាទំពាឡើង ។
លើផ្ទះសំពះសូរគួរគាប់ មេបាចាស់ផ្ចាប់មិនដូចឆ្អើង
ទុំត្រូវស្រាខ្លាំងតាំងចចើង ឫកពារហាក់ថ្កើងដំឡើងគ្រូ ។
ដំឡើងគ្រប់សព្វរាប់រៀបរាយ ច្រៀងថាទាវអោយគ្មានគិតគួរ
គេចវេះស្ងប់ទុំដេកទទូរ បងឡើងមកយូរហើយមិនយល់ ។
ទាវទុកមុខស្ងួតរីងរីត ទាវឆ្លើយឆ្លងឥតមានឆ្ងាយឆ្ងល់
ថាអ្នកថ្លៃប្អូនសូន្យទុំពិល មកដល់ដៀលថាមេត្តាខ្ញុំ ។
ឥតមានហេតុសោះស្រណោះគ្រប់ រាល់ពេលថ្ងៃយប់ទុំអើយកុំ
សង្ស័យសង្ស្ការករុណាសុំ លន់តួវាយដំខំក្បៀណក្បៀយ ។
៨០៥. ទុំថាឱទាវស្រស់នួនល្អង នួនល្អហ្មត់ហ្មងដូចចរណៃ
បងមកដល់យូរគួរអាល័យ ទាវថ្លៃលាក់ខ្លួនពួនដល់ណា ។

ទាវឆ្លើយថាឆាប់ម្ដេចថ្លៃអាយ
បូនម្ទូរបារីចំណើស្លា
ជូនប្រុសថ្ងៃខ្ញុំសុំចិត្តម្ដង
ទន្ទឹមជិតទុំយំតគ្រេង
ទាវទួញយំសោកបោកប្រះប្រាណ
ថ្លាថ្លៃខ្ញុំអើយសមអ្នកអត់
ទុំយំតបថាឱមាសបង
បំណាច់បូនប្រាសចាកចេញខ្ចី
៨១០. ទុំខិតជិតជុំរូមត្រកង
ទាវអាងទុំប្ដីឥតគិតកាញ់
ទុំថាមាសបងដងស្រាមក
កល្យាណទៅក្រុងគាល់ព្រះមហា-
ទាវស្ដាប់សាស័ព្ទទុំស្រដី
ដងស្រាអោយផឹកទាវមើលមុខ
ទាវចរចូលក្នុងកំឡុងឋាន
ននៀលប្រមៀលប្រឫបជញ្ជាំង
នាងម្ដាយទាវទប់ឈប់មិនបាន
ទោសាទោសៈមកបាំងបិទ
៨១៥. ស្រែកថាអរជូនខ្លួនមានបុណ្យ
ចាប់អាទុំចោរចិត្តមានះ
ហៅអស់ពួកក្រុមនាំវាឆាប់
ធ្វូន់ផ្ទះធ្វូន់ដីអប្រិយត្រូវ
ហ៊ានហួសនរនាថមារយាទវា
គៀកកកូនអញពុំលែងឡើយ
ថើបថែសព្វសាច់ច្របាច់ដោះ
បូននេះខ្វល់ខ្វាយខ្លាំងខ្លោចផ្សា
បូនចេញដងស្រាពីសាលេង ។
មាត់តែសាសងចេញទន្ទេង
ទុំឈ្វេងប្រណីស្រីកំសត់ ។
រាប់រៀបដើមដានបានសន្ទត
ស្រឡាញ់ប្រាកដប្រកែកថ្វី ។
មាសបែកបំណងមកមានប្ដី
ខិតមកបងបីស្រីសម្លាញ់ ។
បីហើយថើបផងថាទាវអញ
ខ្លាចគេចាក់បាញ់ចាញ់នរណា ។
បងផឹកសឹមក្រោកនាំកល្យាណ៍
ក្សត្រាទ្រង់ប្រោសសន្ដោសទុក្ខ ។
ហុចស្លាបារីទុំស៊ីជក់
ឆ្អែតឆ្អល់ខ្វល់ចុកវិតក្កខ្លាំង ។
ប្រះប្រាណសោយសោកទុក្ខភាន់ភាំង
ខ្លះរូតរនាំងខ្ទាំងខ្ទប់ជិត ។
មោហ៍មកបាំងប្រាណអោយងងឹត
មិនគិតមិនគន់ធន់មិនឈ្នះ ។
មិនគិតកែកុនឆាប់រហ័ស
ទាញពីលើផ្ទះទំលាក់ទៅ ។
ចាក់បាញ់សម្លាប់កុំអោយនៅ
កើតកើ្តអាស្រូវឥឡូវហើយ ។
ពុះពារអាងអីអាឥតត្រើយ
ហើយទាវអោយឆ្លើយកើយប្រឡែង ។
គ្មានគិតកើ្តកោះម៉្លោះអាឯង

បីថើបសម្រើបធ្វើជាល្បែង
កាលអើយកាលណោះឯអរជូន
បង្កើតអកុសលដល់អាត្មា
៨២០. ទុក្ខម្ដោទោម្នេញខ្នាញ់ឆុរឆាវ
ចូលចាប់ចាក់កាប់ឥតជំនុំ
ទាវឮគេថាចោមចាប់ប្ដី
ទុំថាទាវអើយសមបងបែក
គេចាប់វាយដំក្រំសព្វសាច់
ឈាមកកខាន់ស្ទះបម្រះស្ដី
នៅចុះណាំនួនស្ងួនសម្លាញ់
ស្លាប់គឺគាត់ម្ដាយកំចាយកូន
ទាវឮអង្វរគេទៅថា
ចងទុំលោកកុំចងនឹងផ្ដៅ
៨២៥. គេចោមចាប់ទុំចងនឹងខ្សែ
គិតផ្សោគប្រណើដល់តិចគ្មាន
ទុំឈឺជម្ងឺងឿងងឹតមុខ
ដូចស្រែកទឹកពេកណាឆ្ងាយពោះ
សោះសោកវិយោគយំខ្សឹកខ្សួល
ប្រណម្យបង្គំព្រះរតន៍ត្រៃ
ម្ចាស់អើយបើខ្ញុំនឹងមរណា
ផាត់ទាត់ទោសទុក្ខសុខដោយឡែក
មនុស្សចាប់ចំណាប់ពួកពូកែ
វាប្រាប់ថាទុំខំភាវនា
៨៣០. នាំដល់ខាងថ្មល់នៅទីល្ហាល
ប្រះប្របហាបផុតរលត់ឈឹង
គ្មានចេះវង្វេងក្រែងនរណា ។
ម៉ឺនងួនជាកូនគិតរៀបការ
ឥតមានករុណាមេត្តាទុំ ។
កន្ទ្រាក់បានដាវស្ទុះចូលជុំ
ចងទុំក្រញឹតស្លឹតស្លាបសេក ។
ក្ដួលក្ដៅទាវស្រីទឹកសង្វេគ
បងលាទៅដេកលើផែនដី ។
ឈាមហូរគ្មានដាច់បែកសិរសី
ផ្ដែផ្ដាំទាវស្រីប្ដីលាបូន ។
គេចាក់គេបាញ់បងស្លាប់សូន្យ
អោយសូន្យបាត់ឈ្មោះមិនរស់នៅ ។
សូមលោកករុណាមេត្តាទៅ
ចងនឹងឈ្នួតខ្មៅប្រោសប្រទាន ។
ចាក់មុខបង្អែរឥតគិតធ្យាន
ធ្វើទោសបំពានឥតមានខុស ។
ឈាមចុកឆ្អល់សៀតក្ដៅដូចស្រុស
សាច់សុសធ្លុះសាច់ដាច់សរសៃ ។
ដុនដាបដល់ដួលអួលលើកដៃ
ទ្រទ្រង់សព្វថ្ងៃថ្លៃអនេក ។
សូមម្ចាស់ជួយជាបន្ទាយដែក
សូមចែកចាកបានឋានសួគ៌ា ។
មានគួរខ្លះដែរជូនកាចជា
យកព្រះធម្មាវេលាហ្នឹង ។
បៀតពោធិដើងខាលដួលភ្លឹកភ្លឹង
ខ្យល់ចេញរឹងៗសន្ធឹងស្ដូក ។

ស្លាប់ផុតរលត់សង្ខារា
តំបន់នៅជុំជាមនុស្សលោក
ស្រឡាញ់ស្ពាលស្និទ្ធឥតមានមោះ
សម្លាប់សង្សារនាលោកិយ
មនុស្សនាំទុំយកទៅសម្លាប់
ដល់រោងដល់ផ្ទះសំពះគ្នា
លុះពេលវេលាជាយប់យូរ
នាងនោភីល្បៀងឆ្មៀងសំដែង
៨៣៥. ពួគេខ្សឹបខ្សៀវជៀវជុំ១
ពេលស៊ីកំណត់គេព័ទ្ធចាប់
ទាវព្ទនោស្តីថាប្តីស្លាប់
ឱប្រុសសម្លាញ់ពេលស្នេហា
ប្អូនស្តាយប្រុសថ្លៃអាល័យពេក
ពេលស៊ីប្អូនអត់បទតែទុក្ខ
ទុំអើយប្រុសធ្លាប់រាប់អានខ្ញុំ
ប្អូនចាំមើលផ្លូវរាល់ខែថ្ងៃ
តាមខ្ញុំប្រុសទុំមិនដាច់ចិត្ត
ទៅចោលក្នុងព្រៃថ្លៃពន្លក
៨៤០. ប្រុសយកប្រើថពីជាពូកខ្នើយ
បាំងជាពិដានស្មសានព្រៃ
ទុំអើយម្លេះហើយទាវមិនរស់
ម្តាយឥតមេត្តាករុណាកូន
ម្លេះហើយម៉ែអើយម៉ែនៅចុះ
ឥឡូវម៉ែចិត្តដូចចិនឆៅ
អើនឹងខ្លួនម៉ែការនឹងគាត់
រូបទុំអនិច្ចាដូចដំបូក
រាប់អានគរគោកឃោតប្រណី ។
ទុំស្លាប់នេះខុសពីព្រោះស្រី
លោកអើយគប្បីវេះវៀងវៀរ ។
ស្រេចស្រាប់ក្រឡាប់មកម្ដីម្ដា
សួរសងសន្ធនាគ្រានោះឯង ។
ទាវដេកទទូរទុក្ខចំបែង
ទាវអើយបងឯងតេងលបស្តាប់ ។
ថាចាប់យកទុំទៅសំលាប់
នាំទៅប្រញាប់ដូចចិន្តា ។
ទាវស្ទុះឡើងឆាប់ស្រែកទូញថា
ប្រុសអើយកាលណានឹងយល់មុខ ។
ស្តាយណាស់នឹងដេកធ្មេចមិនលក់
ទុំឆុកឆោតឆុងផុងដល់ក្ស័យ ។
មិនដែលវាយដំហេតុអាល័យ
ស្តាយណាស់ប្រុសថ្លៃសង្ស័យមក ។
ដល់បង់ជីវិតគេនាំយក
ទុំអើយអ្នកជ្រកដេកដោយដី ។
ទុំអើយប្រុសយកពពកខ្មី
ត្រឈីងត្រឈៃព្រលឹងប្អូន ។
សូវស្លាប់តាមប្រុសអោយសោះសូន្យ
មិនដោយដំបូន្មានប្រដៅ ។
ខ្ញុំរស់គ្រាន់ម៉ែរាប់រកហៅ
កើតក្តៅព្រោះខ្ញុំមិនព្រមងួន ។
ទទួលកំណត់រួចប្រុងខ្លួន



បទអុយប្រថុយគ្សិតជូបជូន
ខ្ញុំសូមលាស្លាប់ថ្ងៃនេះជាក់
នោះហើយខ្ញុំផ្សងនឹងផ្ដេកផ្ដោះ
៨៤៥. ទាវផ្ចប់ឈប់អង្គផ្ចង់ចិត្តខ្មី
ប្រណម្យហើយមានវាចាថា
ព្រះធម៌ព្រះសង្ឃអង្គអរហន្ត
អង្គឥន្ទទេវិន្ទទាំងទេវបុត្ត
ខ្ញុំផ្សងបំណងនឹងលាក់ខ្លួន
បាំងខ្ញុំកុំអោយមាននរណា
នោអើយសូមនោបងអាណិត
នោបានកាំបិទចេញទាំងសង
ដល់វាលចូលព្រៃរំពៃទុំ
ឃ្វាលគោក្របីក្រែងស៊ីស្រូវ
៨៥០. ទាវសួរដោយគួរហើយសាស័ព្ទ
ប្អូនទៅដល់ផ្ទះអ្នកជាម្តាយ
កំពុងតែស៊ីខ្លះគេផឹក
អស់លោកចាស់ទុំស្តាប់ខ្ញុំវ៉ា
មូលមួយនឹងគ្នាជាបិប្រាណ
ដែលលោកយកទុំទៅប្រល័យ
ចាំណាំក្មេងណាំបងលាអ្នក
ទាវដើរទៅដល់យល់ជ្រងោ
ទាវប្រះប្របប្តីដៃប្រវ៉ា
ត្រូវដាច់បំពង់កក្ស័យពិត
៨៥៥. ទាំងបីស្រីប្រុសស្រុះខាងស្លាប់
ឯខ្មោចស្រី១ស្លាប់ព្រោះទុំ
ភ្ញៀវមកក្រាស់ក្រួនងួនកម្លោះ ។
ដូចហាក់អកុសលផ្តល់ផ្តាច់សោះ
នៅកុំស្រណោះណាំនោណាំ ។
លើកហត្ថទាំងទ្វីដាក់សិរសា
ខ្ញុំសូមនមស្ការដល់ព្រះពុទ្ធ ។
នៅក្នុងបច្ចុប្បន្នសូមចំហុត
សូមជួយឆាប់ឆុតដូចសច្ចា ។
ពឹងពូនអោយបាត់សូមទេវតា
យង់យល់ដូចថាចិន្តាផ្សង ។
ទៅយកកាំបិទស្លាអោយផង
បំណងចរចុះឆ្ពោះដើរទៅ ។
ឃើញក្មេងជៀវជុំវាលេងនៅ
ទាវឈរស្រែកហៅមកប្រញាយ ។
ថាចូរប្អូនស្តាប់បងរ៉ាប់រ៉ាយ
ក្មេងអាយចូលដល់ទាល់ផ្ទះការ ។
រអឹកចូរប្អូនអ្នកច្រៀងថា
លោកការនរណាទាវទៅក្ស័យ ។
ស្លាប់ក្នុងស្មសានតាំងពីថ្ងៃ
ស្លាប់តែហោងហោមក្រោមដើមពោធិ ។
យកចិញ្ចៀនពាក់ដើរឃ្វាលគោ
ខ្មោចទុំហៅនោយកកាំបិទ ។
បានកាំបិទស្លាអាឆ្វៀងឆិត
ក្បៀកកិតកើយគងទំនងជុំ ។
ខ្មោចទុំគេកាប់គ្មានជំនុំ
ទៅជុំចាក់កអន្តរធាន ។

តាំងថ្លែងពីក្មេងតែងចាំជាក់ ពាក្យទាវលក្ខណ៍ចាំមិនមាន
ភ្លេចសោះចំពោះឡើងរុករាន វាហ៊ានអង្គុយប្រថុយថា ។
ច្រៀងជ្រួចគ្រលួចគ្រលែងក្បាល នៅក្នុងកណ្ដាលវង់ភ្លេងការ
ស្រែកឡើងគន្លេងហៅមេបា ឱអស់លោកតាលោកយាយខ្ញុំ ។
ស្តាប់ចុះប្រុសស្រីសេចក្តីហ្នឹង រំពៃរំពឹងគួរឈប់កុំ
លោកការនរណាទាវជ្រងំ ផ្តាំខ្ញុំមកប្រាប់ស្លាប់មូលគ្នា ។
មេបាខ្លះស្តាប់មិនទាន់ជាក់ ទំលាក់ចានចោលឈរក្រទា
ថាអ៊ីយកុំមាត់ចាំស្តាប់វា ស្ទុះមកម្នីម្នាធ្វើក្រញូវ ។
៨៦០. សួរថាអាវ៉ាច្រៀងម្តងទៀត សង្កិនសង្កៀតអាកូនឪ
អោយច្បាស់បានបាយស៊ីឥឡូវ បើត្រូវមិនអីទេអានាង ។
ក្មេងច្រៀងម្តងទៀតត្បៀតសំលេង លាន់ឮប្រែផ្សេងឆ្លើយវាសវាង
លោកអើយទុំទាវស្លាប់ជង្រ្កាង ស្លាប់ទាំងទួននាងនៅខ្ញុំស្រី ។
ខ្ញុំស្រែកស្រាបាយតាអើយយក សុំបាយមួយស្លកមានចំណី
មានសាច់ជ្រូកក្តាន់មាន់ទាត្រី ក្មេងស៊ីចំណីលេងស្ដីសោះ ។
នាអ្នកទាំងឡាយប្រញាយទៅ មើលក្នុងលំនៅឈ្មោកក្បៀនកោះ
រកទាវនិងនៅឥតចន្លោះ មិនអស់ចិត្តជឿក្មេងស្រដី ។
កញ្ចាស់ជាម្តាយក្រហាយប្រាណ ក្តៅដូចភ្លើងក្រានឆេះឆ្អួលស្រី
ម្តាយទាវទទ័រញ័រសិរសី ស្លើតស្លក់ឥតបើឥតបានយល់ ។
៨៦៥. ជាទុក្ខមុខស្លូតរួតរឹងខឹង ក្រញេវក្រញ៉ឹងរឹងខ្វាយខ្វល់
ជេរគេឥតក្រែងថាង៉ែងស្គាល់ ដឹងទេនៅផ្ទាល់ផ្សៀងមើលវា ។
ទាំងអស់មេឯងឥតគំនិត កំណើតទុកចិត្តវារាល់គ្នា
មេចោរចើកចាប់កាប់ពុះពារ អំបែកក្បាលជាប្រាំពីរភាគ ។
ហងឯងហ៊ានអោយកូនអញបាត់ មិនមានប្រយ័ត្នបានតែពាក្យ
ជំហរតែភូតស៊ីចុះរាក ងងាកឃើញប្រុសស្ទុះចន្លន់ ។
មិនដឹងអីសោះគំលោះពាល ឃើញហើយរោលរាលចើកគ្មានអន់



ហ៊ានមនុស្សប៉ុនគ្នាមើលមិនទាន់ ហងហ៊ានថាភាន់ដូចមាន់ទា ។
មេដែងបាវខ្ញុំជុំប៉ុន្មាន ឆ្លើយថ្កានថាធំកុំខំពារ
យើងមនុស្សមិនខ្មោចទេរាល់គ្នា ទាវជាកូនគាត់ប្រាកដថា ។
៨៧០. នាងចុះទៅនោះជុះទេតើ យើងខ្ញុំបានស្ញើគ្រប់ប្រការ
ប៉ុន្តែប្រកែកថ្មីយាយតា ធម្មតាឬមនុស្សខុសចិត្តគេ ។
ឯយាយហ្នឹងទៀតឆ្លៀតរៀបទាវ ធម្មតាឈាមរាវគ្មានចេះគ្មេរ
ខឹងខ្លាំងទៅតាមខូចមិនមេ បាជេរប្រដៅហៅតែស្តី ។
គ្មានចេះស្តាប់យកពាក្យនរណា យាយតាទៀតដែរដឹងសេចក្តី
ទាវនេះជាក់ច្បាស់ជាមានប្តី ហ្លួងប្រោសប្រណីថ្មីមិនដឹង ។
ម្តាយទាវស្តាប់ជាក់ស្ទើរធ្លាក់ថ្លើម ទាវអើយពីដើមកូនចិត្តរឹង
កូនកាត់ពីម្តាយឆ្ងាយដូចផ្អឹង ម្តាយរឹងនឹងព្រោះចំពោះប្រាប់ ។
ម្តាយថាអោយកូនស្ងួនទៅគេ ម៉្លេះហើយគេជេរគេចាក់កាប់
គេបាញ់គេបោះគេកោះចាប់ សម្លាប់ទៀតទេគេផ្តាសា ។
៨៧៥. ម្តាយនឹងប្រថុយខុសអុយចុះ អោយតែកូនរស់បានរៀបការ
បំណាច់អរជូនបង់បណ្ណា ចិញ្ចៀនខ្សែចារ៉ប្រាផ្កាជូន ។
អោយកូនពាក់ទ្រង់អង្គកាយា របស់គេថាជាជំនួន
ឥឡូវមាសថ្លៃទៅក្សយសូន្យ ទាវកូននាងទុកតែគ្រឿងគ្រប់ ។
កាលនោះម្តាយទាវទុក្ខម្នាក់ឯង ចំបែងវិលវល់ខ្វល់មិនឈប់
ដើរដួលខ្វាញ់ខ្វល់ទាំងថ្ងៃយប់ គិតសព្វដើរទៅហៅគេឯង ។
កាយនោះអស់មនុស្សការប៉ុន្មាន ចោលចានដបល្អីចាប៉ីច្រែង
ចោលផ្ទាំងចោលខ្លះរះទាត់បែង ខ្លះសែងសាច់គោស្ងោរស្រុសស្រាប់ ។
ភ័យខ្លួនពួនជ្រកក្រត់រកហៅ កូនចៅទៅផ្ទះរហ័សឆាប់
ចូលព្រៃរំពៃខ្លាចគេចាប់ សម្លាប់ដូចទុំជិនុំគ្នា ។
៨៨០. ឧកញ៉ាអរជូនងូនកូនគាត់ ខឹងណាស់ខំអត់ស្ទុះម្នីម្នា
ចរចេញទៅដល់ទើបស្គាល់ជា ទុំទាវនៅវាមរណាពិត ។

ចូលទាញខ្មោចទុំដែលរុំនៅ គិតគ្នាយកទៅកប់អោយជិត
ស្រាយយកផាហ៊ុំមកពិនិត្យ យល់ជ្រុះធ្លាក់ស្បិតគិតសង្ស័យ ។
លូកហត្ថប្រញាប់ចាប់លាកលា មើលដឹងស្គាល់ជាបន្ទូលថ្លៃ
អរជូនភ័យខ្លួនខ្លាចលើកដៃ សំពះនិស្ស័យដល់ចៅស្តា ។
កប់ខ្មោចវិលមកបានដល់ផ្ទះ ចង់ឈ្នះហៅម្តាយទាវប្រាប់ថា
កញ្ចាស់ចោរចើកបើកចង្កា ហ៊ានពេកណាស់សារប្រាជ្ញាវ៉ា ។
ឃើញអញមានទ្រព្យផ្តាប់តម្រូវ ថាដូចបង្ហូចពូជមាយា
មារយាទកញ្ចាស់ច្បាស់ជាក់ជា បញ្ចូលអ្នកងារទាំងវ៉ាឯង ។
៨៨៥. រឿងនេះបើថ្លែងរឹងវែងទៅ អង់ស្លេះឈប់នៅមិនសំដែង
យើងនឹងតាំងទៀតឆ្នៀតចារចែង នឹងថ្លែងពញាពេជ្រលេចពូនព្រៃ ។
ពូនប្រឋខ្លួនខ្លាចបុណ្យអរជូន អាងូនជាកូនគិតប៉ភ្លៃ
បំផ្លាញជីវិតទុំគិតតែ គិតកើតមានភ័យដល់រាល់ប្រាណ ។
ពេជ្រគិតថ្មោះស្រេចត្រាច់ម្នាក់ឯង ក្នុងព្រៃកគ្រោកគ្រែងត្បែងដើងក្រាន
ឈើទាលឈើទាបក្នុងស្មសាន ចុះថ្កានដល់ទូកប្រាស់ស្លុកស្លឹង ។
ជាទុក្ខមុខស្លូតរូតរឹងរឹត ភ័យភិតស្មើរបែកបាត់ព្រលឹង
ព្រលប់យប់យូរស្ងាត់សូន្យឈឹង ពេជ្ររឹងសង្វេគបែកបាត់ទុំ ។
ពេជ្រផ្ទប់មិនបានប្រាណរិតក្ត នឹងដេកមិនលក់មុខក្រៀមក្រំ
លើកដៃគងថ្ងាសស្រឡះយំ ទុំអើយចោលខ្ញុំក្រំចំបែង ។
៨៩០. ស្រឡាញ់ប្រាកដក៏ព្រាត់ទៅ ទុំអើយពេជ្រនៅតែម្នាក់ឯង
បួនដេកដោយជីព្រៃគ្រោកគ្រែង សត្វសត្វក្អែកខ្លែងតែងជាគ្នា ។
ខ្ញុំនាំប្រុសថ្លៃទាំងថ្ងៃយប់ មិនឈប់ដើរលេងគ្រប់វេលា
តាំងតែពីយើងនៅវិហារ ជំឋិតជុំជាមិនដែលឃ្លាង ។
មិនដែលមានបែកចែកចាកឋាន លុះបានហ្លួងទ្រង់ជ្រាបជាម្តង
ទុំអើយយើងចូលគាល់ក្សត្រច្បង ប្រលងចំណោះចេះជាងគេ ។
ហ្លួងទ្រង់សណ្តោសប្រោសប្រណី ប្រទានទាវស្រីព្រះទ័យត្រេរ



មេត្តាទុំពេជ្រគេចមិនថេរ ងូនឯងបង់កេរ្តិ៍ចំណេរទៅ ។
ពញាពេជ្រគេចមុខទុក្ខទូញយំ លើកដៃបង្គំប្រណម្យនៅ
ថាខ្មោចទុំអើយប្អូនឥឡូវ ថ្ងៃនេះខុសត្រូវខ្ញុំសូមលា ។
៨៩៥. ទុំអ្នកនៅចុះប្រុសថ្លៃខ្ញុំ ចរទុំកុំចងពៀរវេរា
ឡើងទៅសោយសុខឋានសួគ៌ា យើងសូមជួបគ្នាជាតិក្រោយទៀត ។
នេះនឹងស្រដីដំណើរពេជ្រ វិះរៀបធៀបគេចមានស្មើស្មៀត
ថ្នាំថ្លែងពេជ្រទុក្ខតឹងចង្អៀត ខំឆ្លៀតឆ្លើយប្រាប់បង្គាប់គ្នា ។
ជាគូកនភឿនតឿនប្រញាប់ ពេជ្រប្រាប់ថាស្រាយទូកម្ចីម្នា
ពាក់ចែវបង្គោលដោលចេញជា កុំអោយយូរយាររាចេញទៅ ។
កនពេជ្រស្រុះស្រេចស្រិបរញ៉ី កាប់ចែវផ្អើលត្រីរត់ស្លុងស្លោ
ខ្លះមុជខ្លះហែលចូលជ្រកស្មៅ ចែវកាត់សំដៅជ្រោលន្លង់ ។
សន្ទឹមលេចដល់ក្បាលកោះស្វាយ សុរិយទេវឆ្ងាយបែរបៀតវង់
ចំទិសបច្ចិមមេជ្រសំយុង សុរិយាបាត់អង្គក្នុងគីរី ។
៩០០. ខិតខំចែវជឿនលឿនទៅបាន ឈប់ទូកសម្រាន្តក្នុងជលធី
អែបអបប្រប្រច្រាំងតាំងគិតស៊ី ពេជ្រនឹកដើមទីទុំកំសត់ ។
ពេជ្រពុំស្រេកឃ្លានគ្មានស៊ីសោះ រីងរីតស្រណោះផុសប្រាកដ
នឹកដើមដល់ទុំយំខំអត់ ទុំអើយបងព្រាត់បាត់ទៅណា ។
ពុំឃើញទុំពិតជីវិតថ្លើម ប្រុសឆ្នើមប្រាជ្ញឆ្លៀងបែងបេក្ខា
បែករស់ជាមនុស្សប្រុសមិនថា ទុំប្រាសសង្សារអស់សង្ស័យ ។
ហ៊ានបង់ជីវិតមិនគិតគ្នា ផ្តាច់ប្តូរជន្មាដល់ក្សិណក្ស័យ
គ្មានគិតគ្មាន់ត្អេរគែលកលៃ ព្រោះទាវចង្រៃម្តាយផ្តែផ្តាំ ។
មកដល់អកុសលផ្តល់ទាំងគ្រប់ តែនៅប្រទប់ហេតុមិនចាំ
លោកត្រូគូលេខថាមានកម្ម ពាក្យត្រូវដាក់ដាំថ្នាំឱសថ ។
៩០៥. មួយទៀតដូចដែកដុលប្រហារ វ៉ាយលើនរណាស្លាប់ផុងផុត
មិនគង់ជីវិតដូចកុលបុត្រ តាមធម៌ព្រះពុទ្ធទ្រង់សម្តែង ។

លុះព្រឹកព្រាងព្រះរះសូរ្យសាយ ពេជ្រក្តៅក្រហាយតែម្នាក់ឯង
ប្រាប់គ្នាយើងថាខំស្វះស្វែង ស្រូតរូតតឹងតែងក្រែងពុំដល់ ។
អ្នកចែវប៉ុន្មានមិនបានឈប់ លង់លុះព្រលប់ជិតស្រងល់
ស្រងាត់បាំងបាត់ចូលសកល ទៀបទាល់ក្បែរខាងស្វាងរស្មី ។
រីរៀបប្រដាប់ចាប់ចែវលិ ចរចូលមន្ទីររំពេចខ្មី
ខ្លះបែកទៅផ្ទះសំពះស្តី ស៊ើបសួរគួរបីបត់បែកគ្នា ។
ទើបមនុស្សទាំងឡាយពីអាយជុំ កាលទៅត្បូងឃុំបានសុខជា
ខ្លះប្រាប់ថាទុំគាត់មរណា រួចលាចរចូលព្រះមហាក្សត្រ ។
៩១០. ឡើងដល់ដាក់អង្គផ្ទង់ហត្ថា លើកលើសិរសាក្រាបប្រណិប័តន៍
បង្គំទូលថាទ្រង់ត្រាស់ចាត់ បន្ទូលបញ្ញត្តិសត្វជាខ្ញុំ ។
ក្រោមលួងធូលីទីទុក្ខា អរជូនប្រហារជីវិតទុំ
តាមទ្រង់ប្រណីភ័យបារម្ភ ប្រោសសុំជីវិតឋិតតទៅ ។
ទុំស្លាប់ព្រមគ្នាជាបីប្រាណ ប្រុសស្មានជាទាវនោរស់នៅ
មិនដឹងកាលកម្មនាំមកត្រូវ ឥឡូវទាវនោក៏ស្លាប់ដែរ ។
ស្តេចទ្រង់សណ្តាប់ពេជ្រថ្លាថ្លែង ទ្រង់ខ្ញាល់ស្ងប់ស្ងែងប្រាប់ថានែ
ប្រាប់ក្រុមកាំភ្លើងគ្រឿងសំសែ មហាតលិកដង្ហែអោយរូសឆាប់ ។
ទៅហៅឧកញ៉ាវាំងចក្រី ក្រឡាហោមក្តីអោយប្រញាប់
អោយរៀបទីនាំងតាំងសម្រាប់ ប្រដាប់ជើងទឹកព្រឹកនេះហើយ ។
៩១៥. ប្រាប់កងសេនាពួកទាហាន ពុំមានបង្អង់អោយលង់ឡើយ
ទៅចាប់អាចោរចិត្តឥតត្រើយ ហ៊ានហើយប្រឡេះជាផេះផង់ ។
វាហ៊ានទទឹងហ្នឹងអញច្នោះ ទោសកាប់ស្មោរស្រុសរាស់ជីកបង់
ជីកបុកក្នុងដីក្ស័យរូបអង្គ កុំសង្ស័យសោះអាអរជូន ។
ហ៊ានហែកដុតចោលបន្ទូលអញ ទោសវាចងចាញ់អាងូនកូន
ធ្វើទុក្ខធ្វើទោសអោយអស់សូន្យ សន្តានបងប្អូនបញ្ចូលងារ ។
គ្រានោះនាម៉ឺនរឿនហ្លួងស្តាប់ បន្ទូលថ្លែងប្រាប់ឱនលូនវារ



ថយទៅដល់ផ្ទះជួបជុំគ្នា ជាឆាប់ម្ទីម្នាមិនរារង់ ។
រូសរាន់អោយទាន់តាមបញ្ញត្តិ សន្ទូលស្តេចចាត់អោយប្រៀបប្រុង
ប្រៀបប្រាប់ប្រដាប់ទុកបំរុង សព្វសាច់ហាន់ហុងការុងចាន ។
៩២០. ច្រកស្បៀងល្បៀងលំព្រមពួកបោយ ពួកបង់ព្រះស្វោយគ្រឿងប៉ុន្មាន
រៀបរួចរាចូលឡើងទូលថ្កាន ក្សត្រក្សាន្តទ្រង់ជ្រាបរៀបព្រះអង្គ ។
ទ្រង់អស់គ្រឿងគ្រប់សព្វសុទ្ធមាស មកុដកែវសោភាសស្រស់បញ្ចង់
ទ្រង់ព្រះទម្រង់វជីរផ្ទង់ ពាក់មាស១០ស្រង់ស្រប់ភក្ត្រា ។
ស្រាប់ស្រេចស្តេចគង់ប្រថាប់នៅ ត្រាស់ហៅមហេសីស្រីកញ្ញា
ត្រាស់ទ្រង់ថានង្គនួនជីវ៉ា ជីវិតកនិដ្ឋានបាបុត្រច្បង ។
នៅចុះណាំនួនស្ងួនពន្លក កុំភ្ជួកទឹកគិតរលឹកបង
នួនអ្នករក្សារាជស្នាប់ស្នង វាំងវេនក្រុមកងពួកពលពង្ស ។
រលឹកដាស់តឿនរឿនក្នុងក្រៅ ចាត់ហៅប្រយ័ត្នប្រយោជន៍គង់
កើ្តឈ្មោះចំពោះលើឆោមយង់ រ៉ាប់រងចាំចាត់ភ្លាត់រក្សា ។
៩២៥. អញទៅមិនយូរប៉ុន្មានទេ វិលវិញឆាប់ដែរកុំសង្កា
ត្បិតអញទ្រង់រាជ្យជាក្សត្រា នៅចុះព្រះមហាអគ្គមហេសី ។
ផ្តាំស្រេចសម្តេចព្រះរាមរាជ ទ្រង់មានអំណាចលើផែនដី
ផែនដិន្ទទេវិន្ទព្រះចក្រី យាងចាកចុះទីលីលាដល់ ។
យាងយាសវាសវង់វាំងជុំបី អស់ពលសេនីយ៍តាំងតម្កល់
តម្កើងគ្រឿងហែក្បែរខាងថ្កល់ ទៀបទាល់ទីនាំងតាំងភូមា ។
បីបទប្រាកដបាញ់កាំភ្លើង ក្សត្រថ្កើងយាងឡើងគង់នាវា
ទីនាំងសម្រាប់ព្រះរាជា ពលចុះជុំគ្នារាចែវចេញ ។
ទន្ទេងទន្ទាំលលាំទៅ ស្លុងស្លៅលឿនលយក្រោយប្រដេញ
ប្រជិតទីនាំងក៏ស្លុងស្លេញ លលេញលលោលលាន់ក្នុង ។
៩៣០. គង្គានាវាព្រះមហាក្សត្រ ពួកពលពិផាតក៏ប្រៀបប្រុង
ប្រលោកប្រលែងព្រះឆោមយង់ ប្រាជ្ញប្រុងបើកបទប្រាកដថា ។

សកវាទីឪណាំព្រះចមភព　ជាមួយគ្រប់គ្រងដែនទិសា
ព្រះចៅរាមរាជអំណាចក្លា　ចេស្តាអនុភាពប្រៀបពុំបាន ។
សកវាទីព្រះពាយផាយពពក　សាត់មកបាំងសែងព្រះសូរ្យឆាន
ត្រជាក់ហាក់អ្នកបក់ផាត់ប្រាណ　ម្ចាស់ក្សាន្តព្រះទ័យឥតអ្វីឡើយ ។
សកវាទីយើងខ្ញុំក្រមុំក្មេង　សម្លេងមិនមានណាំម្ចាស់អើយ
ត្បិតយល់ងុយងប់ឈ្លប់ណាស់ហើយ　ប្រកើយស្តេចកងទំនងស្រួល ។
ទើបស្តេចប្រែអង្គទ្រង់ត្រាស់ផ្ទំ　សម្ងំពុំក្សាន្តវិតក្កខ្វល់
វិតក្កគ្មានល្ហែអន់អាក់អួល　ប្រែប្រួលក្រោកក្រេសរវៀសរវៃ ។
៩៣៥. វរល់ខ្វល់គិតដល់ម៉ឺនឯក　ស្លាប់បាត់ខ្ចាត់បែកព្រះជៀសជ័យ
ចៀសចាកចោលក្សត្រស្ងាត់ព្រះទ័យ　មមៃមមាញឹកនឹកដល់ទុំ ។
ដល់ទៀតហៀបហាក់ត្រជាក់ទន់　សុរិយេបៀតមណ្ឌលប្រជុំ
ប្រែជិតងងឹកពួកបោយភ្ញុំ　បង្គំលើហត្ថចាត់ហុចគ្នា ។
ថ្វាត់ថ្វាយព្រះស្ងោយស្តេចសោយក្សាន្ត　ក្រមការប៉ុន្មានប្រជុំគ្នា
មេដែងក្មេងស្រីប្រាំបីជា　តែសព្វគ្រប់ពារគ្រប់ពេលផ្ទំ ។
ចូលដល់គាល់អង្គព្រះចមចក្រ　ចមចៅរឹទ្ធិស័ក្តិអង្គបរម
គាល់ជិតបៀតអង្គករផ្ទង់ផ្ទំ　សម្លេងក្រមុំគ្រសំសាយ ។
សកវាទីយើងខ្ញុំបង្គំគាល់　បង្គំជិតផាល់ព្រះឆោមឆាយ
ព្រះឆោមឆើតបាត់ហាក់បែកឆ្ងាយ　បែកបាត់អង្គកាយទ្រង់ស្តាយទុំ ។
៩៤០. ស្តេចស្តាយឆ្ងាយប្រាណពុំបានសុខ　ប្រះផ្ទំមិនលក់ភក្ត្រក្រៀមក្រំ
ជព្រាំរលឹកស្ទើររលំ　មិនសមបីបែកបង់អសារ ។
អសោចិខ្លោចខ្លាំងភាំងម្តងៗ　ក្សត្រច្បងទ្រង់ផ្ទបខំកម្លា
ពួកពលប៉ុន្មានដែលត្រូវការ　ប្រឹងព្រួយត្បិតការរាជការស្តេច ។
ចៃវព្រះទីនាំងទាំងគែសាយ　គេហៅមិនឆ្ងាយលឿនរដាច់
រដែតតាមក្រោយរដយត្រាច់　រហិចរហាលបានដល់កោះ ។
រៀបរៀងអោយទៀងទូលចមភព　ជាមួយផែនដែនសែនស្រណោះ



សេនាទាំងឡាយក៏រាប់អស់　ចេញស្មោះគិតស្មានប្រមាណចាំ ។
ទ្រង់សួរកោះនេះតើឈ្មោះអ្វី　សូមទានពុំចេរតាមចំណាំ
ព្រៃកពោធិតាឯកព្រៃកតាអាំ　វការទោតាមទៅរកគ្នា ។
៩៤៥. ស្តេចសួរដោយគួរថាអ្វីទៀត　នាយព្វបែរបៀតទូលម្ចីម្នា
ក្រាបទូលត្រើយខាងជើងនឹងយារ　ជ្រុះកងភ្នាក់ងារជាយូរថ្ងៃ ។
សួរស៊ើបទើបអ្នកម្ចាស់កងឆ្លើយ　អ្នកអើយជ្រុះគ្រង់ហ្នឹងអ្នកថ្លៃ
ក្រាបទូលគេយកពាក្យឧបមេយ្យ　ប្រស្រ័យអោយឈ្មោះចំពោះត្រង់ ។
អ្នកទូលស្រួលទៅតាមប្រថុយ　ប្រោសហ្នឹងព្រៃកកុយទូលព្រះអង្គ
ទៅមុខនោះទៀតមិនបែកបង់　តម្រង់តម្រូវឥឡូវដល់ ។
ឈ្មោះស្រុកផ្លូកជ្រៅត្រូវជាម្តង　ព្រៃកពាមជីកកងទូលគ្មានសល់
រាប់ខាងទៅលើឥតទើសទាល់　សកលទៀតទេរដីហៃហើយ ។
ទៅទៀតដល់ភ្លាមពាមផ្កាយម្រេច　ទើបស្តេចតើនចាកបន្ទំស្បើយ
ស្រឡះស្រប់ស្រង់ពុំលង់ឡើយ　ទ្រង់សួរពេជ្រឆ្លើយទូលសាសាង ។
៩៥០. ពេជ្រប្រែឆ្ពោះភ័ក្ត្រហាក់ខ្វាល់ខ្វេវ　វាចូលស្នងស្លេវក្រាបទូលឆ្លង
ថាទានស្ទាក់ស្ទើរប្រោសក្រោមលួង　ល្ងាចណាស់ជាម្តងយាងពុំបាន ។
ទើបអស់ពួកពលក្រុមព្រះស្ងោយ　ពួកបោយរៀបភោជន៍ស្ងោចខាត់ចាន
ខាត់កែប្រដាប់ទាំងប៉ុន្មាន　ដាក់គ្រឿងពេលស្នានកំសាន្តសោយ ។
ចាត់ហៅក្រុមភ្លេងក្មេងពិផាត　រើសរករូបស្អាតចូលមកអោយ
ជួបជុំគ្រប់គ្នាប៉ុន្មានដោយ　អង្គយលេងលយលេចព្វលាន់ ។
សកវាទីព្រះមហារាមរាជរឹទ្ធិ　លើត្បូងជីវិតព្រះទ័យគ្មាន
ប្រទានអោយយល់អោយយើងទាន់　សោភ័ណសុភាពរៀបរៀងទៅ ។
សកវាទីឪផ្កាក្រវាន់ព្រៃ　រសៀលឧទ័យក្រអូបនៅ
ក្រអែបក្លិនខ្ទែបដល់យប់ជ្រៅ　ឥឡូវចិន្តាប្រាថ្នាយាង ។
៩៥៥. ម្ចាស់អើយមានបុណ្យធ្ងន់អនេក　ព្រះដំណើរឡើងស្អែកភ្លឺបំព្រាង
ព្រះសូរ្យសាយសត្វច្រវាត់ភ្លាង　ទ្រង់រាងរៀវតូចស្រស់ច្រឡឹង ។

ច្រឡំទេវបុត្តច្បុតយក
ទើបត្រាស់ថ្កានថាបើយើងនឹង
ឡើងទៅផ្លូវណារាជកានេះ
ថាទានក្រាបទូលកុំរួសឆាប់
ទ្រង់គង់ចាំចាត់ព្រះបន្ទូល
រាជទូតអោយស្រួតរូតលិលា
កែនកងប្រជាជនទាំងឡាយ
បើរឹងទទឹងយកគ្នាចាប់
៩៦០. ស្តេចទ្រង់សណ្តាប់អស់យោធា
ថាអាចាត់ឆាប់កុំគិតក្រែង
នាម៉ឺនពួកក្រុមផ្គុំលើហត្ថ
រួចបោះសង្ហារចាត់នាំទៅ
ចម្រើននាំព្រះបន្ទូលដល់
អរជូនរៀបរួចអស់បណ្តា
ឧកញ៉ាអរជូនកូនប្រពន្ធ
រន្ធត់ញ័រមាត់ហាត់ហៀបក្ស័យ
ខំស្ទុះប្រញាប់ចូលក្នុងឋាន
តម្រួតថ្កល់ត្រង់រងទាំងប្រាំ
៩៦៥. លើហត្ថប្រណម្យផ្គុំទាំងសង
ដាក់ដល់តម្កល់លើសិរសា
ប្រុងផ្ទៀងចាំស្តាប់សព្វបន្ទូល
ធ្វើថ្កល់តម្កល់អោយត្រឹមត្រូវ
បម្រើនានាំបន្ទូលស្តេច

ពិសូគ៌ាមកទើបដូថ្លឹង
រំពឹងរំពៃរៃប្រញាប់ ។
នាម៉ឺនឈប៊ិះទូលសាស័ព្ទ
ស្តេចយាងប្រថាប់គង់ពន្លា ។
វង្កួរវង្កេរចេរចាត់គ្នា[1]
ដល់នាអរជូនខ្លួនវាស្រាប់ ។
ខ្វល់ខ្វាយធ្វើថ្នល់ផ្លូវប្រញាប់
សម្លាប់កុំទុកមុខវាឯង ។
ក្រាបទូលរាជាទើបត្រាស់ថ្លែង
ចាត់ចែងរួសរាន់ទាន់ឥឡូវ ។
បង្គំស្តេចថ្វាត់សរសេរទៅ
សំដៅរួសឆាប់ច្បាប់រាជការ ។
ឡើងផ្ទាល់លើផ្ទះប្រាប់ទៅថា
ទទួលសង្ហារបន្ទូលថ្លៃ ។
ឮហើយស្ទើរគ្រុនញ័រជើងដៃ
វិស័យមុខខ្មោចខ្លោចខ្មៅជាំ ។
យកបានតុតោងមកប្រចាំ
ចំណាំដោយខ្លាចព្រះចេស្តា ។
ក្រាបរាបជាម្តងផ្គងហត្ថា
សច្ចាទទូលផ្តលក្រាបនៅ ។
ថ្លែងប្រាប់តាមស្រួលអោយធ្វើផ្លូវ
ស្តេចយាងឡើងទៅទតភូមិឋាន ។
អោយអរជូនស្រេចរិលរឹងថ្កាង

១. ច្បាប់ខ្លះថា អនុកូលវង្សកេរ្តិ៍ចេរបាត់គ្នា





យើងឈប់បង្អង់រង់ស្លេះបាន ថ្លែងអរជូនបានដឹងសេចក្តី ។
វិតក្កខ្វាយខ្វល់វល់ក្នុងប្រាណ ប្រមាណជាស្តេចពុំប្រណី
ជាទុក្ខយំសោកបាត់ស្មារតី អញអើយសមបីក្ស័យជន្មា ។
និយាយនឹងកូនប្រពន្ធថា កូនអើបិតាមានវេរា
សមនឹងស្លាប់ខ្លួនទាំងអស់គ្នា វេទនាដល់ប្រាណព្រមជាម្តង ។
៩៧០. សមជាមហាក្សត្រាថ្លៃ យកទោសដល់ក្ស័យត្បិតក្សត្រច្បង
អោយព្រះបន្ទូលមកទុំផង ថាឯងមិនចងចិត្តទុកដាក់ ។
ខ្លបខ្លាចអំណាចព្រះចេស្តា ស្តេចធ្វើទោសាមិនតែម្នាក់
សួរសាច់សន្តានស្មានជាក់លាក់ នឹងព្រះចមចក្រឥតកំបាំង ។
អរជូនជាទុក្ខខ្លាចស្លាប់ខ្លួន ណាព្រួយប្រធូនទ្រង់អោយតាំង
ធ្វើផ្លូវធ្វើថ្នល់ដល់កំលាំង កែនកនចូកចាំងជំរះឆ្ការ ។
ស្រេចហើយអរជូននាំកូនដើរ កែនកងចាត់ប្រើគ្មាននរណា
ហ៊ានទាស់ទទឹងនឹងរាជការ ខ្លបខ្លាចព្រះមហាក្សត្រធិបតី ។
សឹងកាន់ពូថៅខ្វែវកាំបិទ កាប់គាស់ល្បោចល្អិតឈើឫស្សី
នរណាគ្មានប្រុសកោះយកស្រី លើកដីទូលលីបាវរែកសែង ។
៩៧៥. ខ្លបខ្លាចអំណាចបុណ្យបារមី ឮហើយភិតភ័យព្រឺស្ញប់ស្ញែង
អរជូនវិលដល់ផ្ទះសំបែង តាក់តែងរៀងខ្លួនចុះទៅថ្វាយ ។
បង្គំទៀបទាល់ដល់មហាក្សត្រ ប្រយ័ត្នរៀបរកភស្តុទាំងឡាយ
ត្នោតដូងស្លាចេកម្នាស់ខ្នុរស្វាយ ខ្វល់ខ្វាយរកសព្វសត្វក្ល ។
ក្ងោកលលកព្រាបប្រើសព្រៃ សាច់វារ់សរសៃគ្រឿងសម្ល
សម្លាប់យកស្នែកភ្លុកកុយថ្ម ត្រដរព្រួញប្រាណពុំមានឈប់ ។
រកបានភ័ស្តុផលថ្លល់តុតាំង សាច់ឆ្អើរសាច់អាំងរមាំងនប់
រៀបដាក់ដោយឡែកចែកសព្វគ្រប់ ចាត់ហៅជំទប់ជំទាវធំ ។
មូលមកស្រីប្រុសអរជូនចាត់ ហាមអោយប្រយ័ត្នប្រយោជន៍កុំ
យកកូនចៅទៅក្រែងវាយំ ជូនស្តេចទ្រង់ផ្ទំពុំប្រណី ។



៩៨០. រៀបរួចសព្វគ្រប់មិនឈប់ឈរ ទូលលីឈ្មូឈរទាំងប្រុសស្រី
រែកសែងជាលច្រែងថាសតុល្អិ រទេះក្របីដឹកគ្រាប់បេង ។
ថ្វាយក្រុមអស់អ្នកអគ្គមហេសី ដុះលាបមូរបារីស្រីក្មេងៗ
បញ្ចើជជើលព្រើលខាងល្បែង គិតឆ្វេងឈ្មូឆរអរចែកគ្នា ។
ចរចេញពីឋានបានដល់ទៅ ព្រះចៅស្តេចគង់ព្រះពន្លា
នាម៉ឺនតូចធំក្រុមភ្នាក់[១]ងារ គាល់ព្រះរាមាជាចមត្រៃ ។
ចក្រិនមហិន្ទមហោធរ បវរចមចក្រឯកអគ្គំណៃ
ទ្រង់ឥទ្ធិរិទ្ធិជីវិតថ្លៃ គ្រងក្រុងជាញជ័យលើចតុរង្គ ។
ឧកញ៉ាអរជូននាំមហាជន ទាំងកូនប្រពន្ធទៅប្រៀបប្រុង
ជិតទៀបយល់អង្គព្រះឆោមយង់ ស្តេចគង់ជួបជុំក្រុមបរិវារ[១] ។
៩៨៥. នាម៉ឺនចតុស្តម្ភក្រុមកុង្សិយ៍ មាត្រមុខមន្ត្រីគាល់ត្រៀបត្រា
អរជូននាំគ្រឿងបណ្ណាការ ស្មានថាក្សត្រាប្រោសប្រណី ។
ស្រេចលើកគ្រប់គ្រឿងរឿងដង្វាយ លើកហត្ថថ្វាត់ថ្វាយលើសិរសី
តម្កល់ដាក់ត្រឹមប្រជុំបី ស្តេចគ្មានមេត្រីទ្រង់សាទរ ។
សម្តេចរាមរាជអំណាចបុណ្យ រក្សាមហាជនជាជំហរ
គ្រងដែនផែនភូមិព្រមចូលមក៍ ឮខ្ទរសឹងខ្ទាតខ្ទេចជាម្តង ។
ក្រឡេកទតជាក់ហាក់ពុំស្រួល អន់អួលអស្សុជលធារាហ្វាង
មួម៉ៅក្តៅក្តួលរំជួលចង ព្រះទ័យបំណងបំនួននៅ ។
ខ្មាញ់ខ្មួលពុំស្រួលពុំស្រប់ស្រង់ ពុំចង់អោយអរជូនវិលទៅ
មិនល្ហែមិនល្ហើយមិនស្បើយក្តៅ ត្រាស់ហៅយករាជអំណាចខ្លាំង ។
៩៩០. ចូរអស់នាម៉ឺនជំនុំទោស ឃើញកុំសន្តោសអាចោរខ្វាំង
អាចោរខ្មោចចូលប្រមូលអាំង កាន់ក្រាំងកត់ត្រាឃាត់ខាឃុំ ។
ស្តេចមានបន្ទូលប្រាប់កុង្សិយ៍ សេនាបតីអោយជំនុំ

១. ច្បាប់ខ្លះថា ក្រុមសេនា

នាម៉ឺនប៉ុន្មានចូលមកជុំ    បង្គំទៀបទាល់គាល់ផ្គាល់ភ័ក្ត្រ ។
ស្តេចទ្រង់ត្រាស់ថាអស់កុង្សីយ៍    បតីជំនុំរកដោយថ្នាក់
អាណាមានទោសខ្មោះច្រវាក់    ត្រូវដាក់គុកម៉ឺតតិតតាមទោស ។
កុំមានប្រណីស្រីប្រុសប្រើ    ដំណើរឡើងទៅត្រូវកាប់អូស
ឬស្បីឈើក្តីចាំងចូកបោស    រលីងកើបកោសអោយអស់ផេង ។
ជាទីទុកជីកជាអន្លង់    រណ្តៅធំផុតទូលាយវែង
វាយវាត់បន្ទាត់បត់ខ្វាត់ខ្វែង    ដំណែងដំនៀបរៀបអោយហើយ ។
៩៩៥. ចតុស្តម្ភបានស្តាប់សព្ទព្រះប-    ន្ទូលខ្ទាល់ចន្ទន់ពុំលង់ឡើយ
សេនាបតីមន្ត្រីឆ្លើយ    ស្តេចពុំក្សាន្តស្បើយល្ហើយពីទុក្ខ ។
កុង្សីយ៍មួយមានប្រាជ្ញាវាងវៃ    ឈ្លាសយល់សេចក្តីក្រមគ្រប់មុខ
ក្រុមនគរបាលបែកបែងលុក    ត្រូវខ្មោះឬគុកមេស្រុកក្រម ។
បតីមួយឆ្លើយឆ្លងឡើងថា    អាជ្ញាអរជូនមិនគួរសម
អានេះវាចេះតិតសម្ងំ    វាហ៊ានរៀបចំតិតការកូន ។
សេនាបតីមួយទៀតឆ្លើយ    ថាឱអ្នកអើយកុំអ្នកប្អូន
ថានោះត្រូវដែរព្រោះមិនសូន្យ    ទំនៀមពីដូនទូតលួតលា ។
ថាមានជើងក្រោយដោយជើងមុខ    ទោសនឹងត្រូវឆុតពូកកនវា
អរជូនម្តាយទាវឬក្មួយមា    សន្តានពង្សាញាតិកាស្និទ្ធ ។
១០០០.មន្ត្រីជំនុំតាមដោយថ្នាក់    កាត់ដាក់ដោយយល់ស្គាល់សុចរិត
ទៀងតាមក្រមគ្រប់ឈបរិះគិត    ជំជែកល្មោចល្អិតពិនិត្យត្រូវ ។
ក្រមក្រុមជំនុំមិនទាន់ព្រម    មួយឆ្លើយថាល្មមយើងឥឡូវ
អស់លោកកុំកាត់បើមិនសូវ    ព្រមគ្នាតម្រូវខុសទោសប្រាណ ។
សេនាបតីតែងប្រកែក    ថាយើងថ្ងៃស្អែកភ្ញុំទើបបាន
ស្រេចចូលជុំចោទសួរសងសាន    លោកកុំប្រមាណដោយយោបល់ ។
កុង្សីយ៍គិតសព្វមិនថប់សោះ    ថាទោសទាំងអស់លោកកុំឆ្ងល់
ឯមនុស្សដែលមកជួយកង្វល់    គ្នាមកតាមកលតាមគេឯង ។



នឹងខានមិនបានខ្លាចបុណ្យគេ    គេវាយគេដេរគេកំហែង
ទោសអស់មនុស្សនោះខ្ញុំថ្លាថ្លែង    ចាត់ចែងបញ្ចូលជាអ្នកងារ ។
១០០៥.ឯទោសអរជូនកូនប្រពន្ធ    នឹងអស់ទ្រព្យធនគ្រប់ពង្សា[១]
សន្តានបងប្អូនជីដូនវា    ម្តាយទាវព្រមជាតំនិតមួយ ។
ទោសត្រូវកាប់គាស់រាស់ឬភ្នូរ    បោះស្មោរក្នុងខ្ទះអោយរលួយ
រលាករលត់ផុតគេជួយ    ភូឈួយកាត់ឆាប់ប្រាប់ជាម្តង ។
កត់ត្រាបញ្ជាក់ពេលថ្ងៃខែ    ប្រាប់គ្នាហូរហែអោយដឹងផង
ទើបហៅប្រជុំគ្នាមូលម៉ង    ចូលទូលក្សត្រច្បងសងសូត្រថា ។
លើហត្ថាចាប់ច្បាប់ជំនុំ    ដាក់ជើងពានផ្គុំលើសិរសា
ថ្វាត់ថ្វាយចំពោះឈ្មោះបណ្តា    យើងខ្ញុំករុណាកាត់សេចក្តី ។
ព្រះចមចក្រពង្សទ្រង់ទតសព្វ    ត្រាស់វិញត្រឡប់រំពេចខ្មី
ថាអើត្រូវហើយមែនកុង្សីយ៍    ប្រាកដឥតបីបែរបែកបង់ ។
១០១០.ទ្រង់ត្រាស់ប្រាមប្រាប់ប្រញាប់ភ្លាម    ថ្ងៃស្អែកព្រហាមកុំបង្អង់
រៀបរកទីនាំងណាស្លូតត្រង់    ដ្បិតក្មេងស្រីចង់ហែអញទៅ ។
ឧកញ៉ារាជកុលយល់សេចក្តី    ចក្រីចក្រិនទេវិន្ទចៅ
ចមចក្រពង្សមិនគង់នៅ    ក្រើនហៅពួកក្រុមប្រជុំចូល ។
មូលគ្នាជួបជុំប្រាមប្រាប់ថ្វាត់    ថ្វាយព្រះមហាក្សត្រជាតិវង្ករ
ស្តេចយាងឥឡូវត្រូវប្រមូល    ចាត់ចងដំបូលកូបកើយកល់ ។
ប្រដាប់ស្រោមភ្លុកមុខកញ្ចោង    កញ្ចែងញ៉ែងគងក្រពាត់ខ្នល់
ខ្នប់ខ្មើយពូកព្រំហ៊ុមបាំងខ្យល់    ប្រុងប្រៀបថ្កបថ្កល់អង្គព្រះពុទ្ធ ។
រករៀបទីនាំងតាំងប្រដាប់    សំរាប់គ្រឿងភ្ជិទីវិសុទ្ធ
ទីនាំងដាក់ព្រះមុនបំផុត    តែងតាមដោយបទពីព្រេងមក ។
១០១៥.កាលអើយកាលនោះឯអង្គព្រះ    រាមរាជតេជះតបះពន្លក
ពន្លឺកស្ងប់ស្ងែងស្តេចយាងក្រោក    ពួកពលចុះស្រោកគរកាន់គ្រឿង ។

១. ច្បាប់ខ្លះថា ពង្សា

មហាគលិកលាវិលយ៉ាងលំដាប់
ស្តេចគង់ហត្ថីរស្មីគ្រឿង
អស់ពួកនារីស្រីអ្នកក្នុង
បរក្រោយស្តេចគង់ទ្រង់ចិញ្ចៀង
នាម៉ឺនចតុស្តម្ភក្រុមសេនីយ៍
ខ្លះជិះសេះសបរក្បៀវក្លា
ហែហមអមបាំងក្លស់ភិរម្យ
ទាហានរានរុកមុខចចើង
១០២០.ដល់ហើយត្រៀមត្រៀបរៀបហែស្តេច
ទ្រង់ទតភូមិស្ថានរាស្ត្រប្រជា
ពួកកងសេនាបណ្តាស័ក្តិ
រៀបរៀងខុនណាងក្មេងជំទង់
បើកបទប្រាកដតាមដំណើរ
ឆ្លាស់ឆ្លើយស្រែកឡើងចាំទទួល
សកវាទីឱណាំអនិច្ចាចិត្ត
ម្ចាស់យើងយាងមកភ្នកព្រះទ័យ
ទៀងទតសកលដល់ត្បូងឃុំ
ធ្លាប់សព្វព្រះទ័យព្រះទ្រង់រិទ្ធិ
១០២៥.សកវាទីឱណាំផ្កាកំភ្លឹងព្រៃ
ទសពិធមានរិទ្ធិឥតទប់ទល់
សកវាទីឱណាផ្កាចំប៉ី
សង្ឃាតយាងដល់កម្មអ៊ីបែក
អនិច្ចាសទ្រង់ប្រោសសណ្តោសខ្ញុំ
រកថ្ងៃបលំហើយព្រោះស្ទុះក្តៅ
ព្រះចមចក្រពង្សទ្រង់កំសាន្ត

មុខក្រោយស្រៀបស្រាប់រិទ្ធរុងរឿង
ភ្លឺផ្លេតព្រាតព្រៀងភ្លឺស្ទប់ស្វែង ។
ជិះហត្ថីមង្គលទីតែង
បញ្ចើតតរអែងក្រែងនរណា ។
សឹងជិះហត្ថីហែក្សត្រា
កាន់គ្រឿងថ្លៃថ្លាស្ទាកាំភ្លើង ។
ត្រសាយត្រសុំសប្បាយថ្កើង
ហែឡើងតាមថ្នល់ដល់ពន្លា ។
តម្រេចយាងត្រាច់ចរលីលា
យាងយាសឡប់រាប្រថាប់គង់ ។
ធំតូចដោយថ្នាក់រូចរៀបរង់
ប្រៀបប្រុងប្រាមប្រាបក្រាបទទួល ។
សរសើរអោយត្រូវតាមទំនួល
សម្រួលតាមភ្លេងសម្លេងស្រី ។
មុខគួរអាណិតត្បិតប្រណី
ដោយក្តីស្នេហាចិន្តាគិត ។
បាត់ទុំកំសត់ប្រាកដពិត
គួរស្តាយជីវិតឥតបានយល់ ។
ស្ងប់ស្ងួតព្រះទ័យទសពល
ទ្រង់ខ្វល់ឆ្ងល់ឆ្ងាយស្តាយអនេក ។
ចំពប់ដោយក្តីទ្រង់សង្វេគ
សង្វេគរាល់ខ្លួនបំនួននៅ ។
បង្គំអម្ចាស់លាកលាទៅ
រួចហៅគ្គីគ្គាលីលាលេង ។
ត្រាស់ថ្កានព្រះអង្គបញ្ឈប់ភ្លេង



នូវក្រុមកុមារីស្រីក្មេងៗ
ទ្រង់ត្រាស់កំហែងថ្លែងឱង្ការ
ជំនុំកាត់ទោសអោយត្រឹមត្រូវ
១០៣០.នគរបាលបង្គំព្រះចក្រី
ធ្វើតាមទោសានុទោសសត្វ
ជីកល្អុងក្នុងដីជ្រៅច្រហ
ប្រាំពីរសណ្តានច្រានកូនចៅ
ទើបយកក្របីទីមរនាស់
នគរបាលបែងមិនប្រែងវា
ចែងចាត់អ្នកទោសដែលធំៗ
ត្រូវស្ទោរឥឡូវទោសអ្នកអើយ
ដុតភ្លើងដាំទឹកពន្លឺកពុះ
ឆេះលេចអណ្តាតផុតជើងក្រាន
១០៣៥.រលត់ផុតខ្យល់ដល់សង្ខារ
រលាយជីវិតខ្លួនមួយៗ
វិលវល់អំពល់ក្នុងសង្សារ
គួរយកទុក្ខតាំងវិរះឈ្វេង
ព្រោះអនត្តាថាសូន្យសោះ
នរណាធ្វើប្រាបដរាបត្រូវ
ចូរអស់មហាជនជាតិស្រីប្រុស
បានមើលស្តាប់ដឹងក្នុងច្បាប់ថ្មី
ដើមដានប្រមាណតាមបញ្ញា

ស្តេចថ្លែងត្រាស់ថាអោយចេញទៅ ។
ត្រាស់ថាយមរាជអាចតម្រូវ
ហើយហៅនគរបាល[១] ឆាប់ថ្វាត់ ។
ត្រាស់ខ្ញីស្ទុះភ្លាមទៅចែងចាត់
ត្រូវចាត់ផាត់មូលចូលរណ្តៅ ។
ប្រមាណត្រឹមករួចចាត់ហៅ
សាច់ផៅភពផុងក្នុងវេទនា ។
ដែកដឹករួចរាស់ទោសមួយឃ្លា
កម្មពៀរវេរាស្ងាលាហើយ ។
ប្រជុំចូលដល់ពុំលង់ឡើយ
ឥតមានចំលើយចំលើប្រាណ ។
ដាក់ឧសបង្ករខ្ពស់ប្រមាណ
បោះប្រាណផ្លែប្លិចលិចរលួច ។
អនិច្ចំអនិច្ចានរណាជួយ
ទុក្ខព្រួយព្រោះកម្មនាំវង្វេង ។
រាល់រូបបណ្តាវាចាលេង
អនិច្ចំនោះឯងពុំទៀងនៅ ។
ពុំដឹងត្រើយកោះនឹងស្លាប់ទៅ
ចុះជ្រៅលិចលង់ក្នុងអវិចី ។
កើតមកជាមនុស្សក្នុងលោកិយ
ចូរមានស្មារតីគិតអោយយល់ ។
ព្រះទ័យសត្ថាចង់បានផល

១. សាស្ត្រាស្លឹករឹតថា (អង្គរបាន) ក្លាយតាមសម្តីអ្នកស្រុកពីបុរាណ ។

បានភព្វប្រសព្វសឹងមិនឆ្ងល់ គ្មានទិទើសទាល់លស់សេចក្តី[1] ។
១០៤០.ថ្លាថ្លែងសម្តែងរឿងបទបាឋ សង្វាតកើតកបក្នុងជាតិ
ជាតំតំណាំងនាលោកិយ ទោះបិសិស្សសង្ឃអង្គសាមណេរ ។
សំណាក់ក្នុងពុទ្ធសាសនា អាចារ្យចេះស្ដីបាលីប្រែ
រីអ្នកច្បាស់ជាក់រឿងហូរហែ ចេះតែអធិប្បាយស្រាយស្រង់ស្រួល ។
ដំណើរទាវទុំផ្ទុំចងជា និទានយូរយារអន់អាក់អួល
មិនត្រង់មិនត្រូវតាមទំនួល ប្រែប្រួលត្បិតពាក្យងាករិលរល់ ។
ចូរជនយកកាយនូវវាចា វាចិត្តកុំថាប្រមាណយល់
ប្រមើលឃើញស្រាប់ច្បាស់កុំឆ្ងល់ តំកល់ទុកតតំណរទៅ ។
គិតថាលោកគ្រូបុទមត្ថេរ ព្រះសង្ឃវរវង្សគង់នឹងនៅ
ទីឋានអារាមវត្តកំព្រៅ ដោយខ្ទៅខ្ទីឃ្លៀងឃ្លៀងវោហារ ។
១០៤៥.សន្មតថាចត់សព្វសេចក្តី ថ្លាថ្លែងអំពីកាលក្សត្រា
ស្ដេចយាងចុះចាកក្រឡាប់សា ឧកញ៉ាគ្រប់ក្រុមផ្ទុំមិត្តមូល ។
ទើបស្ដេចយាសយាងគង់ទីនាំង ពួកពលខ្លះខ្លាំងថៃវចេញខ្ទួល
ខ្មីឃ្លាតសង្វាតស្រុះស្រើបស្រួល ជ្រះជ្រោងដង្ហួលទំនួលដល់ ។
ស្ដេចយាងឡើងគង់វង្សវរៈ ចមចក្រពង្សស្ដេចគង់ស្គល់
ពួកក្រុមនិកាយមិនឆ្ងាយឆ្ងល់ បូរដែនសកលរចល់ជុំ ។
ក្រាបលាក្រស័ត្រកាត់រកផ្ទះ កូនចៅរហ័សថាឱអ៊ី
អញ្ជើញទៅដល់ខេត្តត្បូងឃ្មុំ ជំនុំទោសស្រេចស្ដេចវិលដល់ ។
គង់ក្នុងរាជវាំងតាំងទសពិធ អំណាចរឹងរឹទ្ធិទ្រង់ស្អាងផល
ជរាបៀតអង្គផ្ទង់តម្កល់ អកុសលកាយកម្មចាំចងជល់ ។
១០៥០.រលាយរលត់ផុតសង្ខារ មិនទៀងឋានណាត្បិតមិនយល់
បន្ទូលមិនមានមិនបានផ្ដល់ តាមផលសំណោងសាងមកស្រាប់ ។
**ឯទំ** តែងតាំងតាមវោហារ យើងសន្មតថាទុកជាច្បាប់
ស្រេចនូវប្រការជាអណ្ដាប់ សាសព្វថែងចប់ម្ល៉េះឯងហោង ។

---

១. ចាប់ពីនេះទៅដល់ចប់ យើងបានផ្ទៀងផ្ទាត់ដូចច្បាប់ដើមឡើងវិញ ព្រោះបោះលើកមុនមានការកាត់ចោលខ្លះ ។